Fevrier-2008.qxd 2/20/2008 11:19 AM Page 1


# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១ ថ្ងៃទី០១-៣១ ខែមីនា ឆ្នាំ២០០៨ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ **លេខ ០៧**


ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

## មាតិកា




**បទពិសោធន៍យុវជនក្នុងមុខងារអប់រំជំនឿ** ទំព័រ ៧



**អង្គការការីតាសក្នុងភូមិភាគបាត់ដំបង** ទំព័រ ៨



**សិល្បៈច្រៀងចំរៀង អាយ៉ៃ** ទំព័រ ១២


# ចំណាប់អារម្មណ៍របស់យុវជនលើមជ្ឈមណ្ឌលបុប្ផាណា

ទំព័រទី១០...



Photos :





កម្មវិធីវិទ្យុ

**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : **FM 99.5 Mhz** ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : **FM 91.0 Mhz** ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: **FM 102.5 Mhz** ១០:០០-១១:០០ ថ្ងៃ សៅរ៍/អាទិត្យ
កំពង់ធំ : **FM 88.5 Mhz** ម៉ោង ១២:០០-១២:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : **FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : **FM 100.5 Mhz** ម៉ោង៧:៣០-៨:០០ យប់ថ្ងៃសៅរ៍

Fevrier-2008.qxd 2/20/2008 11:20 AM Page 2

# រូបថតសម្រាប់ខែនេះ


Photo : L. Samphors

លោកកាឌីណាល់អូ ប្រែន ទីប្រឹក្សាសម្តេចប៉ាប និងជាប្រធានអង្គការការីតាសអន្តរជាតិថតរូបអនុស្សាវរីយ៍ជាមួយលោកអភិបាលអេមីល និងបូជាចារ្យបប់ ក្នុងពិធីថ្វាយអភិបូជានៅព្រះសហគមន៍សន្តយ៉ូសែប នាឱកាសដំណើរទស្សនកិច្ចលោកមកកាន់កម្ពុជាកាលពីដើមខែកុម្ភៈនេះ **(ឆ្វេង)**

យុវនារីពិការដែលបានទទួលការបណ្តុះបណ្តាលជំនាញចម្លាក់ នៃក្រុមសហជីវិនព្រះយេស៊ូ នៅមណ្ឌលបន្ទាយព្រាប ដែលស្ថិតនៅឃុំត្រពាំងវែង ស្រុកអង្គស្នួល ខេត្តកណ្តាល បង្ហាញស្នាដៃខ្លួនដោយឆ្លាក់រូបសំណាកព្រះនាងម៉ារី និងអាចលក់ផងដែរ **(ក្រោម)**

ក្រុមអ្នកទទួលការអប់រំជំនឿ រួមនិងលោកអេមីលដេតម្ប អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក្នុងពិធីជំហានទីពីរនៅព្រះសហគមន៍ផ្សារតូច ដែលប្រព្រឹត្តឡើងនាថ្ងៃទី០៩ ខែកុម្ភៈ។ ក្នុងឆ្នាំនេះ អ្នកទទួលជំហានទីពីរ នៅភូមិភាគបាត់ដំបងមានចំនួន ៨៤នាក់- ភូមិភាគភ្នំពេញចំនួន ២២នាក់ និងភូមិភាគកំពង់ចាម ១៧នាក់។ **(ក្រោម)**


Photo : L. Samphors


Photo : L. Samphors

គ្រីស្តបរិស័ទនៃព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន ភ្នំពេញ ស្ម័គ្រចិត្តធ្វើការបរិច្ចាគឈាមដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាមដើម្បីជួយសង្គ្រោះជីវិតជនរងគ្រោះ កាលពីថ្ងៃទី១៧ កុម្ភៈ។ **(ក្រោម)**


Photo : L. Sovanna

គ្រីស្តបរិស័ទនៃព្រះសហគមន៍បឹងទំពុនចុះឈ្មោះ និងពិនិត្យសុខភាព មុននឹងធ្វើការបរិច្ចាគឈាម។ តាមគម្រោងការរបស់គណៈកម្មការសុខភាពនៃភូមិភាគភ្នំពេញ ការបរិច្ចាគឈាមនឹងធ្វើឡើងរៀងរាល់ ៤ខែម្តង នៅបឹងទំពុន និងផ្សារតូច។ **(ឆ្វេង)**


Photo : L. Sovannna



# វិចារណកថា

## រួមគ្នាថែរក្សាវប្បធម៌ ជាមួយប្រជាជនខ្មែរ


Photo : DR

**លោកបូជាចារ្យ អូមែរ ហ្សឺរ៉ាល់ដូរ ប្រធានមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក (CSC)**

សម្តេចប៉ាបយ៉ូហាន ប៉ូល ទី២ បានរិះគិតថា : "វប្បធម៌ណាក៏ដោយ តែងខិតខំស្វែងយល់ពីអាថ៌កំបាំងនៅក្នុងពិភពលោក និងមនុស្សគ្រប់ជាតិសាសន៍ទាំងអស់ ដែលបង្ហាញពីសមត្ថភាពគ្មានកំណត់របស់មនុស្សគ្រប់ជាតិសាសន៍។ ខ្លឹមសារសំខាន់នៃវប្បធម៌ គឺជាការស្វែងយល់ពីអាថ៌កំបាំងដ៏អស្ចារ្យនៃព្រះជាម្ចាស់"។ ព្រះសហគមន៍កាតូលិកក្នុងប្រទេសកម្ពុជាលើកទឹកចិត្តដល់ប្រជាជនកម្ពុជាដែលខិតខំប្រឹងប្រែងសង្គ្រោះ និងការពារកេរមរតកវប្បធម៌ខ្មែរ ឱ្យបានគង់វង្សបន្ទាប់ពីភ្លើងសង្គ្រាមផ្ទៃក្នុង។ នៅមហាសន្និបាតបុរីវ៉ាទីកង់ ទី២ នៃព្រះសហគមន៍កាតូលិកក្នុងលិខិតមួយដែលមានឈ្មោះ **Gaudium et Spes** បានបញ្ជាក់ថា : "មនុស្សគ្រប់ជាតិសាសន៍យើងអាចបំពេញលក្ខណៈជាមនុស្សបានត្រឹមត្រូវតាមរយៈវប្បធម៌ប៉ុណ្ណោះ" ដែលនាំឱ្យយើងបានយល់ដឹងពីសារៈសំខាន់នៃវប្បធម៌ ហើយជាតិសាសន៍មួយនឹងមិនទទួលផលប្រយោជន៍ទៅអនាគតបានទេ បើគ្មានវប្បធម៌ដ៏រឹងមាំមួយនោះ។ ចំណែកព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ក៏មានឆន្ទៈចូលរួមយ៉ាងសកម្មជាមួយប្រជាជនកម្ពុជា ដើម្បីជួយថែរក្សាការពារលើកតម្កើង និងជួយសង្គ្រោះវប្បធម៌ខ្មែរ ដែលមានភាពត្រចះត្រចង់តាំងពីដើមរៀងមក។ ហេតុនេះហើយ ចូរយើងបន្តកសាងបច្ចុប្បន្ន និងអនាគតឱ្យក្មេងៗ ជំនាន់ក្រោយក្នុងការថែរក្សាកេរមរតកវប្បធម៌ឱ្យបានខ្ពង់ខ្ពស់ និងស្ថិតស្ថេរ។

**សូមបញ្ជាក់ផងដែរថា :** ក្នុងនាម អ្នកនាំសារ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបងប្អូនដែលបានសរសេរលិខិតផ្ញើមកកាន់ការិយាល័យយើងខ្ញុំ ដើម្បីលើកទឹកចិត្តចំពោះការបោះផ្សាយកាសែតព្រះសហគមន៍ គឺអ្នកនាំសារដែលមានខ្នាតធំជាងមុន។ យើងមានទិសដៅដ៏ពិតប្រាកដក្នុងការធ្វើឱ្យរីកចម្រើននូវគុណភាពកាសែតរបស់យើង ដើម្បីបំពេញនូវសេចក្តីត្រូវរបស់សង្គមជាតិខ្មែរ។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com;

Website : www.catholiccambodia.org;

ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្សឺរ៉ាល់ដូ។

ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា។

Licence ១៨៣ ពម.ប្រក./២៥-មិថុនា-២០០៧

**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៨ ថ្មី ដែលជាចម្រៀងកោតសរសើរព្រះយេស៊ូគ្រីស្ត និងយុវជនផងដែរ។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ ប្រសិនប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងទូរស័ព្ទ : **០១២ ២៤៤ ៧៧៨។**

# មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មនឹងគិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទូរស័ព្ទ : **០១២ ៣៧៧ ៤៦០។**

### សារសម្រាប់មិត្តអ្នកអាន!

បើប្រិយមិត្តចង់មានប្រតិកម្មទៅលើអត្ថបទ មានចម្ងល់ ឬចង់ជូននូវមតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាស័យដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវចម្លើយដោយក្តីរីករាយ។



**សេចក្តីជូនដំណឹង !** គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ និងដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត សូមទំនាក់ទំនងការិយាល័យអ្នកនាំសារ ឬទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។ បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយរបស់អង្គភាព-ក្រុមហ៊ុន ដែលគ្មាន Logo គឺមិនគិតថ្លៃឡើយ។



សូមប្រិយមិត្តមើល និងកំសាន្តជាមួយល្បែងរូបភាព នៅទំព័រទី ១៦ រួចទើបមើលចម្លើយនេះ។

Fevrier-2008.qxd 2/20/2008 11:20 AM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

ថ្ងៃអាទិត្យទី៤ ក្នុងរដូវអប់រំពិសេស ( ថ្ងៃទី២ មីនា ឆ្នាំ២០០៨)

## "ខ្ញុំមកក្នុងពិភពលោកនេះដើម្បីវិនិច្ឆ័យចិត្តមនុស្ស គឺមនុស្សខ្វាក់នឹងមើលឃើញ ហើយឱ្យមនុស្សមើលឃើញ ទៅជាមនុស្សខ្វាក់វិញ"

( យ៉ូហាន ៩១-៤១) តាំងពីដើមរៀងមក ព្រះសហគមន៍ជ្រើសរើសថ្ងៃអាទិត្យទី៤ សម្រាប់ធ្វើជំហានទីពីរ ចំពោះអ្នកដែលនឹងទទួលជ្រមុជទឹកនៅថ្ងៃបុណ្យចម្លង។ អត្ថបទព្រះគម្ពីរ ដំណឹងល្អ នៅថ្ងៃនេះ ដែលនិយាយអំពីបុរសខ្វាក់ភ្នែកពីកំណើត គឺនាំឱ្យយើងយល់ពីអត្ថន័យនៃការទទួលជ្រមុជទឹក។ នៅពេលបុរសនោះមើលឃើញវិញ គាត់ហៅលោកយេស៊ូថា "ព្រះជាម្ចាស់" និងជា "ព្រះសង្គ្រោះ"។ ព្រះយេស៊ូយល់ថាបុរសនោះខ្វាក់ភ្នែក ដើម្បីឱ្យព្រះជាម្ចាស់បង្ហាញនូវកិច្ចការរបស់ព្រះអង្គនៅក្នុងគាត់"។ ក្រោយមក ព្រះយេស៊ូបង្ហាញផ្ទាល់ព្រះអង្គ "ជាពន្លឺបំភ្លឺពិភពលោក"។ ព្រះយេស៊ូបានប្រោសបុរសនោះឱ្យមើលឃើញ និងនាំឱ្យបុរសនោះចាប់ផ្តើមជីវិតថ្មី។ ព្រះគម្ពីរដំណឹងល្អនេះគឺសម្រាប់យើងជាគ្រីស្តបរិស័ទធ្វើជា "ពន្លឺរួមជាមួយព្រះជាម្ចាស់" ដូចសន្តប៉ូលនិយាយថា: "ចូររស់នៅឱ្យសមជាមនុស្សដែលមានពន្លឺក្នុងខ្លួន"។ ចូរយើងរិះគិតពិចារណាឱ្យគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយក៏មិនត្រូវចូលរួមប្រព្រឹត្តអំពើឥតប្រយោជន៍ដែលមកពីសេចក្តីងងឹតនោះឡើយ ស៊ូបើកមុខអំពើទាំងនោះឱ្យគេឃើញ។

ថ្ងៃអាទិត្យទី ៥ ក្នុងរដូវអប់រំពិសេស ឬរដូវ ៤០សិបថ្ងៃ ( ថ្ងៃទី០៩ មីនា ឆ្នាំ២០០៨)

## "ខ្ញុំដែលប្រោសមនុស្សឱ្យមានជីវិតថ្មី ខ្ញុំនឹងផ្តល់ឱ្យគេមានជីវិត"

( យ៉ូហាន១១,១-៤១) ថ្ងៃអាទិត្យនេះ ព្រះសហគមន៍បង្ហាញអំពីការរស់ឡើងវិញនៃលោកឡាសាដើម្បីឱ្យគ្រីស្តបរិស័ទនឹករឭក និងត្រិះរិះពិចារណាពីជីវិត និងសេចក្តីស្លាប់។ នៅពេលដែលព្រះយេស៊ូបានទទួលដំណឹងថា លោកឡាសាមានជំងឺ ព្រះយេស៊ូបានប្រាប់សាវ័ករបស់ព្រះអង្គថា ព្រះជាម្ចាស់នឹងបង្ហាញឫទ្ធានុភាព និងសិរីរុងរឿងរបស់ព្រះអង្គ។ ពេលនោះក្រុមសាវ័កក៏រំឭកព្រះយេស៊ូថា ជនជាតិយូដាចង់សម្លាប់ព្រះអង្គនៅស្រុកនោះ។ ទោះបីយ៉ាងនេះក៏ដោយ ព្រះយេស៊ូបានសម្រេចព្រះហឫទ័យយាងទៅកាន់ស្រុកនោះ ហើយប្រាប់សាវ័កថា: "ឡាសាជាមិត្តសម្លាញ់របស់យើងបានស្លាប់ទៅហើយ ខ្ញុំត្រូវតែទៅដាស់គាត់ឱ្យភ្ញាក់ឡើងវិញ"។ ខ្លឹមសារសំខាន់ក្នុងព្រះគម្ពីរ ដំណឹងល្អ ថ្ងៃនេះ គឺជាសេចក្តីប្រកាសរបស់នាងម៉ារីថា: ""បពិត្រព្រះជាម្ចាស់! ខ្ញុំម្ចាស់ជឿជាក់ថា ព្រះអង្គពិតជាព្រះគ្រីស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយគឺពិតជាព្រះអង្គដែលត្រូវយាងមកក្នុងពិភពលោកនេះមែន"។ សេចក្តីប្រកាសនេះ លោកសន្តសិលា ក៏ធ្លាប់បានប្រកាសកាលពីមុនដែរ។

ថ្ងៃអាទិត្យលើកតម្កើងទុក្ខលំបាករបស់ព្រះយេស៊ូ "បុណ្យហែស្លឹកទៅដល់បុណ្យចម្លង" ( ថ្ងៃទី១៦ មីនា )

## "ឱ! ព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ"

( ម៉ាថាយ ២៦,១៤-២៧,៦៦) នេះជាថ្ងៃអាទិត្យដ៏សំខាន់ក្នុងរដូវអប់រំពិសេស ដែលនាំឱ្យយើងជាគ្រីស្តបរិស័ទធ្វើបុណ្យព្រះយេស៊ូសោយទិវង្គត និងការមានព្រះជន្មរស់ឡើងវិញដោយសិរីរុងរឿង។ ចូរយើងរួបរួមជាមួយព្រះយេស៊ូនៅពេលព្រះអង្គរងទុក្ខលំបាក និងសោយទិវង្គតយ៉ាងសែនអាម៉ាស់ដើម្បីសង្គ្រោះមនុស្សលោកឱ្យរួចពីបាប នាំឱ្យយើងឆ្លងផុតពីបាបកម្ម និងជីវិតទាសកឱ្យមានសុភមង្គល និងសេរីភាព។ ព្រះយេស៊ូរងទុក្ខលំបាក មិនមែនគ្រាន់តែលើផ្នែករាងកាយប៉ុណ្ណោះ គឺផ្នែកខាងផ្លូវចិត្តផងដែរ ដោយសារមនុស្សរាល់គ្នាបានបោះបង់ព្រះអង្គចោល ហើយភាពស្ងាត់ពីព្រះបិតា នាំឱ្យព្រះយេស៊ូស្រែកដង្ហោយថា: "ឱ! ព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ"។ យើងរិះគិត នៅអាទិត្យនេះថា ព្រះយេស៊ូសង្គ្រោះមនុស្សយើងដោយសារ "ព្រះអង្គបានលះបង់អ្វីៗទាំងអស់ មកយកឋានៈជាទាសករ" (លិខិតភីលីព២,៦-១១) ហើយបានបំពេញដោយផ្ទាល់ព្រះអង្គពីព្រះវិញ្ញាណនៃព្រះបិតាដែលមានន័យថា ព្រះយេស៊ូទីពឹងលើសេចក្តីស្រឡាញ់នៃព្រះបិតា។ ហេតុដូច្នេះហើយ ការទទួលសោយទិវង្គតរបស់ព្រះយេស៊ូ មិនមែនជាការបរាជ័យនោះទេ ដោយសារព្រះបិតា បានសង្គ្រោះព្រះបុត្រាពីសេចក្តីស្លាប់ និងនាំឱ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញដោយសិរីរុងរឿង។

## សម្រាប់កុមារ


Photos: DR

ប្អូនៗជាទីរាប់អាន នៅក្នុងអ្នកនាំសារលេខមុន យើងបានដឹងថា ព្រះយេស៊ូត្រូវមាល្បួងនៅក្នុងវាលរហោឋានអស់រយៈពេល ៤០ថ្ងៃ ហើយព្រះអង្គបានជម្នះនូវការល្បួងនេះ។ នៅក្នុងព្រះសហគមន៍កាតូលិក រដូវមួយដែលមានរយៈពេល ៤០ថ្ងៃ មុនបុណ្យចម្លង គឺបុណ្យព្រះយេស៊ូរងទុក្ខលំបាក និងមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង។

**តើរដូវនោះគេហៅថា រដូវអ្វី?**

នៅក្នុងព្រះសហគមន៍កាតូលិកមានរៀបចំជារដូវផ្សេងៗក្នុងមួយឆ្នាំ ដើម្បីជួយឱ្យគ្រីស្តបរិស័ទរិះគិតពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងរិះគិតអំពីការរស់នៅរបស់ខ្លួន។ រដូវទាំងនេះមានដូចតទៅ: រដូវរង់ចាំ និងអបអរបុណ្យព្រះយេស៊ូប្រសូត រដូវធម្មតា រដូវអប់រំពិសេស (ដែលពីមុនគេធ្លាប់ហៅថា រដូវត្រណម) និងរដូវបុណ្យចម្លងជាដើម។ រដូវដែលមានរយៈពេល ៤០ថ្ងៃ មុនបុណ្យចម្លង គឺរដូវអប់រំពិសេស (ដែលគេធ្លាប់ហៅថា រដូវត្រណម) ដោយចាប់ផ្តើមពីថ្ងៃពុធ បុណ្យរោយផេះ។

**ហេតុអ្វីរដូវនេះមានរយៈ ៤០ថ្ងៃ?**

ដោយសារពេលព្រះយេស៊ូរងការល្បួងព្រះអង្គបានតមអាហារជាយូរថ្ងៃ។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទកាតូលិកវិញ នៅក្នុងឱកាសរដូវ ៤០ថ្ងៃនេះ មានការតមអាហារ អធិដ្ឋានច្រើន និងធ្វើពិធីសម្រុះសម្រួលលើកលែងទោស-ល-។ នៅក្នុងរយៈពេលនេះដែរ មានបីចំណុចសំខាន់ដែលត្រូវធ្វើគឺ: ទីមួយ ការរៀបចំបងប្អូនដែលស្វែងយល់ថ្មី ដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងពេលបុណ្យចម្លង។

ទីពីរ ជារយៈពេលមួយយ៉ាងសំខាន់ដើម្បីជួយឱ្យគ្រីស្តបរិស័ទនឹករឭកអំពីទង្វើនៅក្នុងការរស់នៅរបស់ខ្លួន ជាគ្រីស្តបរិស័ទ តើបានប្រព្រឹត្តសមរម្យជាគ្រីស្តបរិស័ទឬទេ? បានយកចិត្តទុកចំពោះអ្នកជិតខាងដោយសុភាពរាបសាឬយ៉ាងណា? តើខ្លួនយើងបានខិតខំប្រណិប័តន៍តាមព្រះបន្ទូលរបស់ព្រះយេស៊ូដោយសមរម្យដែរឬទេ? ទីបី ជាពេលសម្រាប់បងប្អូនដើម្បីកែប្រែចិត្តគំនិត និងពង្រឹងជំនឿរបស់ខ្លួន។



# ព្រឹត្តិការណ៍ប្រចាំខែ


Photos: P. Samphy

## បញ្ចប់ពាក្យចចាមអារ៉ាមជនបរទេសមានសិទ្ធិកាន់កាប់ដីធ្លី

សម្តេចនាយករដ្ឋមន្ត្រី បានបញ្ចប់ពាក្យចចាមអារ៉ាមមួយ កាលពីថ្ងៃទី ១៤ កុម្ភៈ ដែលថា រដ្ឋាភិបាលគ្រោងនឹងដាក់ចេញច្បាប់១ ដែលអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកាន់កាប់ដីធ្លីមួយរយភាគរយនៅកម្ពុជា។ សម្តេចហ៊ុន សែន បានបញ្ជាក់ថា: "ខ្ញុំចង់និយាយទៅកាន់បងប្អូនជនរួមជាតិថា យើងពុំដែលសុបិន ឬពិចារ-ណាអនុម័តច្បាប់១ដែលអនុញ្ញាតឱ្យជនបរទេសទិញដីកម្ពុជានោះទេ"។ ដោយឡែករដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ក៏មិនបានអនុញ្ញាតឱ្យជនបរទេសកាន់កាប់ដីមួយរយភាគរយដែរ។ សម្តេចនាយករដ្ឋមន្ត្រី បានចាត់ទុកថា ព័ត៌មានចចាមអារ៉ាមទាំងនេះប្រហែលត្រូវបានគេបង្កើតដើម្បីវាយប្រហារ លើរដ្ឋាភិបាលលោកមុនការបោះឆ្នោតខែកក្កដាខាងមុខ។

## គួរឈប់មានលិខិតកំណើតក្នុងពាក្យសុំប្រឡង

សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ បានស្នើសុំឱ្យក្រសួងអប់រំជាតិបញ្ឈប់ឱ្យសិស្សថ្នាក់ទី៩ និងទី១២ បញ្ជាក់លិខិតកំណើតក្នុងការដាក់ពាក្យសុំប្រឡងមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិនាសម័យប្រឡងខាងមុខ។ លោករ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ បានចាត់ទុកថា ការតម្រូវឱ្យសិស្សបញ្ជាក់លិខិតកំណើតដែលត្រូវប្រថាប់ត្រា ដោយអាជ្ញាធរនេះ តម្រូវឱ្យសិស្សម្នាក់ចំណាយប្រាក់ពី ៥០០០រៀល ទៅ ២០០០០ រៀល សម្រាប់សិស្សនៅតាមបណ្តាខេត្ត និង៤០០០០រៀល សម្រាប់សិស្សនៅភ្នំពេញ។ លោករ៉ុង ឈុន ចាត់ទុកថា នេះគឺជាអម្រែកដ៏ធ្ងន់ធ្ងរសម្រាប់សិស្សក្រីក្រ។

## ស្ថានភាពអ្នកកាសែតកម្ពុជាឆ្នាំ២០០៧

សមាគមកម្ពុជាការពារអ្នកកាសែត "សកកអក" វាយតម្លៃថា ស្ថានភាពអ្នកសារព័ត៌មានកម្ពុជា ឆ្នាំ២០០៧ មានភាពល្អប្រសើរច្រើនខាងផ្លូវច្បាប់ក្រោយពីរដ្ឋាភិបាលដកបទបរិហារកេរ្តិ៍ចេញពីក្រមព្រហ្មទណ្ឌ។ ទោះជាយ៉ាងនេះក្តី "សកកអក" កត់សម្គាល់ឃើញថា ករណីគំរាមកំហែង បំភិតបំភ័យដល់អ្នកសារ-ព័ត៌មាននៅកើតមាននៅឡើយ។ យោងតាមរបាយការណ៍ "សកកអក" ចេញផ្សាយដើមឆ្នាំនេះ បង្ហាញថា អ្នកកាសែត ២នាក់ ត្រូវបានសម្លាប់ (ពុំទាក់ទងនឹងការងារកាសែត) គំរាមកំហែង មាន ១៥ ករណី និង បណ្តឹងតុលាការមាន ៩ ករណី។ ករណីចាប់ចង ៨ករណី និង៣ករណីត្រូវព្រមានដោយក្រសួងព័ត៌មាន។ ដោយឡែកអ្នកសារព័ត៌មានម្នាក់ត្រូវបានបណ្តេញចេញពីការងារ។

**រស់ ឱណា**

## សូមឈប់កុហក! សូមឈប់សម្លាប់ទៅ!

"សូមបញ្ចប់ការកុហក! សូមបញ្ចប់ការសម្លាប់!" ជាឃ្លាមួយដែលត្រូវបានបោះពុម្ពនៅលើអាវយឺត និងសរសេរលើបដាជាច្រើនរាប់មិនអស់ ជាមួយនឹងសំឡេងលាន់រំពងដ៏ខ្លាំងៗ នៃការប្រឆាំងតវ៉ាថា: "សូមឱ្យបញ្ចប់ការចាប់ធ្វើជាចំនាប់ខ្មាំង និងសូមឱ្យបញ្ចប់នូវចលនាក្រុមឧទ្ទាម FARC" របស់ប្រជាជនកូឡុំប៊ីទាំងក្នុង និងក្រៅប្រទេសរាប់លាននាក់ ដែលបានប្រមូលផ្តុំគ្នាដង្ហែជាក្បួនធំបំផុតនៅតាមដងផ្លូវសំខាន់ៗ នៃទីក្រុងតូច-ធំ ប្រមាណ១៣០ នៅទូទាំងប្រទេស និងជុំវិញពិភពលោក។ ការដង្ហែជាក្បួន ដែលមានទ្រង់ទ្រាយធំបំផុតមិនធ្លាប់មាននេះ គឺដើម្បីប្រឆាំងតវ៉ានឹងពួកឧទ្ទាមបំបែករដ្ឋកូឡុំប៊ី FARC ដែលធ្វើឡើងនៅថ្ងៃទី០៤ កុម្ភៈ ឆ្នាំ២០០៨ នៅក្នុងទីក្រុងតូច-ធំនៃប្រទេសកូឡុំប៊ី នាទ្វីបអាមេរិចខាងត្បូង ដែលបានកើតមានអំពើហិង្សាដ៏ធ្ងន់ធ្ងរ។ ប្រទេសកូឡុំប៊ីបានទទួលរងការឈឺចាប់ជាច្រើនអន្លើ ដោយសារពួកឧទ្ទាមបំបែករដ្ឋកូឡុំប៊ី បានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មជាច្រើន ដូចជាដុតបំផ្លាញភូមិជាច្រើន ព្រមទាំងចាប់ប្រជាជនកូឡុំប៊ីជាច្រើនពាន់នាក់ ធ្វើជាចំនាប់ខ្មាំងនាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។

**អូមែរ**

## ឯតទគ្គកម្មទុក្ខសោកសម្រាប់អាស៊ាន

បើយោងតាមធនាគារពិភពលោក និងអង្គការសហប្រជាជាតិ លោកស៊ូហាតូ គឺជាអ្នកផ្តាច់ការពុករលួយលេខមួយ។ គេបានប៉ាន់ប្រមាណថា មានការពង្វៀងយកទ្រព្យសម្បត្តិ ពី១៥ ទៅ ៣៥កោដិដុល្លារពីក្រុមបក្សពួករបស់ស៊ូហាតូ ក្នុងរយៈពេល ៣២ ឆ្នាំនៃការកាន់អំណាច។

ចាប់តាំងពីការដួលរលំអំណាចរបស់លោកនៅឆ្នាំ១៩៩៨ បំណងនៃការច្បាមយកមូលនិធិមកវិញត្រូវបានបរាជ័យ។ បើតាមមេធាវីនៃអង្គការតម្លាភាពអន្តរជាតិនៅឥណ្ឌូនេស៊ី ក៏បានឱ្យដឹងថា ការរាំងខ្ទាស់នេះគឺមកពីមរតកនៃអតីតរបបចាស់។ "នៅឥណ្ឌូនេស៊ី គេបានប្តូរប្រព័ន្ធ តែមិនបានដូរមនុស្សឱ្យបានដូចគ្នាទេ។

លោកអគ្គរដ្ឋអាជ្ញានៃប្រទេសឥណ្ឌូនេស៊ីបានអះអាងថា ការប្តឹងចោទប្រកាន់ ដែលសន្យាធ្វើឡើងនៅឆ្នាំ២០០៧ និងបន្តធ្វើទោះបីក្នុងករណីលោកស្លាប់ក៏ដោយ។ តុលាការនៅតែខិតខំស្វែងរកដណ្តើមមកវិញនូវទ្រព្យសម្បត្តិចំនួន៤៤០លានដុល្លារ ហើយនិងសំណងដែលមានចំនួនលើសពី ១,១ កោដិដុល្លារ។ ប៉ុន្តែសេចក្តីសង្ឃឹមនៃការផ្តន្ទាទោសលោកស៊ូហាតូ ហាក់ដូចជាមិនសូវមានទម្ងន់។ "ដំណឹងល្អសម្រាប់អ្នកប្រព្រឹត្តអំពើពុករលួយ... ដំណឹងអាក្រក់សម្រាប់ប្រជាជនឥណ្ឌូនេស៊ី"។

**P.R**

Fevrier-2008.qxd 2/20/2008 11:20 AM Page 6



# ព្រះវិហារបិតចំកណ្តាលចំការកៅស៊ូ

**ដាម៉ូ**

នាថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ កន្លងទៅ លោកអភិបាលភូមិភាគអន់តូនី លោកបូជាចារ្យ សេរ៉ាល់ ក្រុមបូជាចារ្យ ដូនជី និងគណៈកម្មការព្រះសហគមន៍មួយចំនួន នៅព្រះសហគមន៍កំពង់ចាម បានទៅទស្សនាទីតាំងព្រះសហគមន៍បុរាណ ពីរកន្លែង នៅចំកណ្តាលព្រៃកៅស៊ូ ដែលស្ថិតក្នុង ភូមិ១៨ ឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដែលសព្វថ្ងៃនេះត្រូវបានគេបោះបង់ចោល និងលែងមានគ្រីស្តបរិស័ទនៅបរិវេណជុំវិញនោះទៀតហើយ ។
នៅក្នុងចំណោមព្រះសហគមន៍ទាំងពីរ គឺមានមួយកន្លែងបានបន្សល់ទុកនូវប្រាង្គព្រះវិហារមួយ គួរឱ្យចាប់អារម្មណ៍ ដែលប្រជាពលរដ្ឋម្តុំនោះតែងទម្លាប់ហៅថាវិហារយួន ។ តាមសម្តី បងស្រីម៉ារី អាឡែន ដូនជីក្រុមគ្រួសារឧបការគុណម្នាក់ ក៏បានឱ្យដឹងថា បងស្រីធ្លាប់មានកុមារភាពនៅព្រះសហគមន៍នោះ រីឯព្រះវិហារនៅទីកន្លែងនោះ ក៏ធ្លាប់មានឈ្មោះថា "ព្រះវិហារព្រះឈើឆ្កាង" ។ បងស្រីបន្ថែមទៀតថា ព្រះវិហារនេះ ត្រូវបានកសាងសម្រាប់កម្មករចំការកៅស៊ូ ដែលភាគច្រើន ជាជនជាតិវៀតណាម និងមានបូជាចារ្យវៀតណាម ឈ្មោះ ម៉ាយស៊ុនខ្វា ជាអ្នកមើលការខុសត្រូវ ។ សូមបញ្ជាក់ដែរថា សព្វថ្ងៃដីព្រះវិហារនេះជាកម្មសិទ្ធិរបស់រដ្ឋអំណាច ។


Photo: Messenger

លោកបូជាចារ្យ បងប្រុស បងស្រី និងគ្រីស្តបរិស័ទកាតូលិក ថតរូបជាអនុស្សាវរីយ៍ពីមុខសំណាករូងភ្នំ នៅចំកណ្តាលព្រៃកៅស៊ូ ទីកន្លែងដែលព្រះកុមារយេស៊ូប្រសូត



Pictur : Oliver

## មរណភាពរបស់លោកគ្រូតូវ៉ាន់ ហៀប


Photo: Fr. Omer

នៅថ្ងៃទី៤ ខែកុម្ភៈ លោកគ្រូសិលាតូវ៉ាន់ ហៀប នៃព្រះសហគមន៍អ្នកលឿងនៃភូមិភាគកំពង់ចាម បានទទួលមរណភាពនៅប្រទេសវៀតណាមខាងត្បូង ដោយសារជំងឺទឹកនោមផ្អែមយ៉ាងធ្ងន់ធ្ងរ ។
លោកគ្រូហៀប កើតនៅភូមិព្រែកក្របៅ ស្រុកពាមជី ខេត្តព្រៃវែង ។ លោកបានជួយព្រះសហគមន៍ច្រើន ចាប់តាំងពីមុនសម័យលន់ នុល ដែលលោកគ្រូធ្វើជាសមាជិកក្រុមគ្រួសារបព្វជិតព្រះរាជវង្ស ។ បន្ទាប់ពីភៀសខ្លួនទៅវៀតណាម ដោយសារសង្គ្រាម នៅទសវត្សរ៍៨០ លោកគ្រូបានត្រលប់មកកម្ពុជាវិញ និងចូលរួមជួយព្រះសហគមន៍អ្នកលឿងម្តងទៀតដោយធ្វើជាគ្រូអប់រំជំនឿ ដឹកនាំសកម្មភាពយុវជន និងបង្រៀនភាសាខ្មែរ-វៀតណាមឱ្យក្មេងៗ ។ ព្រះសហគមន៍អ្នកលឿង និងព្រែកក្របៅ សូមចូលរួមរំលែកទុក្ខ និងអធិដ្ឋានឱ្យវិញ្ញាណក្ខន្ធលោកគ្រូបានឡើងទៅកាន់ស្ថានបរមសុខផង ។ លោកគ្រូហៀបត្រូវបានបញ្ចុះនៅវៀតណាមតែម្តង ។

**លោកឪពុកអូមែរ**





# បទពិសោធន៍យុវជនក្នុងមុខងារអប់រំជំនឿ

**លី សុវណ្ណា**

ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានចាប់ផ្តើមសាឡើងវិញ ក្រោយពីបាត់បង់ទីកន្លែង និងព្រះវិហារដើម្បីគោរពបម្រើព្រះជាម្ចាស់ជាច្រើនកន្លែងមក ។ ការរស់ឡើងវិញនេះ ព្រះសហគមន៍កាតូលិក ត្រូវចាប់ផ្តើមឡើងវិញទាំងស្រុងក្នុងនោះមានទាំងការពង្រឹងជំនឿដល់គ្រីស្តបរិស័ទនៅ សល់ពីស្លាប់ បន្តជំនឿទៅដល់អ្នកជំនាន់ក្រោយ និងចូលរួមអភិវឌ្ឍសង្គមរួមជាមួយរាជរដ្ឋាភិបាលជាដើម ។
កញ្ញាជឿង ផាន់ណា មានអាយុ ២៦ឆ្នាំ ជាបុគ្គលិកនៃមណ្ឌលវប្បធម៌កាតូលិកកម្ពុជា និងជាអ្នកអប់រំជំនឿដែរនោះ ក៏បានឱ្យដឹងថា នាងបានចូលបម្រើព្រះសហគមន៍ ក្នុងមុខងារជាអ្នកអប់រំជំនឿ រយៈពេល១១ឆ្នាំហើយ បន្ទាប់ពីនាងបានទទួលនូវអគ្គសញ្ញាជ្រមុជទឹកក្លាយជាគ្រីស្តបរិស័ទកាតូលិក ។ ផាន់ណា បានរៀបរាប់បន្តថា ជំនឿមិនអាចបង្ហាញតាមការរៀនសូត្របានទេ ហើយក៏មិនមានត្រឹមតែទ្រឹស្តីទេ គឺរួមមានទាំងការអនុវត្តផងដែរ ការអប់រំជំនឿមិនស្រួលទេ ប៉ុន្តែអ្វីដែលសំខាន់ គឺនាងពេញចិត្តលើមុខងារនេះ ។ នាងសង្កត់ធ្ងន់ថា : "ខ្ញុំរំភើបចិត្តអំពីជីវិតរបស់ព្រះយេស៊ូ ហើយខ្ញុំចង់បន្តជំនឿ និងអំណរនេះដល់បងប្អូនឱ្យសប្បាយដូចខ្ញុំដែរ" ។
ចំណែកយុវជនស៊ុនទីន អ្នកអប់រំជំនឿមនុស្សពេញវ័យនៅព្រះវិហារផ្សារតូច ក្រុងភ្នំពេញ ក៏រៀបរាប់បទពិសោធន៍របស់ខ្លួនថា ក្នុងរយៈពេល ២ឆ្នាំ ក្នុងមុខងារជាអ្នកណែនាំជំនឿ លោកក៏មានការពិបាកខ្លះៗ ។ តែកិច្ចការនេះបានជួយឱ្យជំនឿរបស់លោកផ្ទាល់មានការរីកចម្រើន គឺជំរុញឱ្យលោកត្រូវអានព្រះគម្ពីរ និងរិះគិតពីអត្ថន័យដោយប្រុងប្រយ័ត្ន ។ យុវជនស៊ុន ទីន បន្តថា : "ការអប់រំត្រូវពឹងទៅលើព្រះគម្ពីរលើសៀវភៅកម្មវិធីបង្រៀនព្រមទាំងបទពិសោធន៍របស់ខ្លួនផ្ទាល់ដែរ គឺដូចជា បទពិសោធន៍ក្នុងការរស់នៅជាគ្រីស្តបរិស័ទក្នុងព្រះសហគមន៍កាតូលិក និងក្នុងសង្គមដែលមានបងប្អូនច្រើន ជាពុទ្ធបរិស័ទនោះ" ។ រីឯយុវជនជួ ដាម៉ូ ដែលទើបធ្វើអ្នកណែនាំជំនឿក្នុងខេត្តព្រៃវែង ក៏បានបញ្ជាក់ថា: "វាមានការលំបាកណាស់សម្រាប់ខ្ញុំ ដោយមិនធ្លាប់ និងគ្មានគរុកោសល្យក្នុងការបង្រៀនតែដោយសារជំនឿ ខ្ញុំរីករាយនឹងបំពេញមុខងារនេះ" ។
ចំពោះគរុកោសល្យនៃអ្នកអប់រំជំនឿ លោកបូជាចារ្យប្រាំងស័រ ប៉ុងសូដឺ ជាប្រធានមណ្ឌលវប្បធម៌កាតូលិកកម្ពុជា ក៏បានបញ្ជាក់ថា : "ការអប់រំជំនឿព្រះសហគមន៍កាតូលិក នៅមានភាពទន់ខ្សោយ ។ ព្រះសហគមន៍ បានរៀបចំគម្រោងពង្រឹងគរុកោសល្យដល់អ្នកអប់រំជំនឿរៀងរាល់ខែ រយៈពេល២ ឬ៣ថ្ងៃ គឺចាប់ពីខែមីនានេះទៅ ។"


Photo: L. Samphors

### ដំណាក់កាលនៃការអប់រំជំនឿ

ការអប់រំជំនឿក្នុងព្រះសហគមន៍កាតូលិក មាន៤ ដំណាក់កាល : ដំណាក់កាលមុនចូលក្រុមស្វែងរក ដំណាក់កាលទី១ ក្រុមត្រៀមចូលព្រះសហគមន៍ ដែលមានរយៈពេល១-២ឆ្នាំ ព្រះសហគមន៍អប់រំគេអំពីព្រះយេស៊ូ ការសង្គ្រោះរបស់ព្រះអង្គ និងគ្រីស្តសាសនា និងមានពិធីចូលព្រះសហគមន៍។ គេប្រកាសជំនឿថា យកព្រះគ្រីស្តជាទីពឹង យកព្រះបន្ទូលជាទីពឹង យកព្រះសហគមន៍ជាទីពឹងប្រៀបដូចពុទ្ធបរិស័ទយកព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងដែរ។ ដំណាក់កាលទី២ ក្រុមស្តាប់ព្រះបន្ទូលលាន់ឮឡើង ដែលមានពិធីត្រាស់ហៅ យ៉ាងឱឡារិក។ ដំណាក់កាលទី៣ ក្រុមទទួលការអប់រំពិសេស មានពិធីទទួលអគ្គសញ្ញាជ្រមុជទឹក។ ចំណែកដំណាក់កាលទី៤ គឺក្រុមពន្លកថ្មី។


Photo: L. Samphors

ក្រុមបងប្រុស បងស្រី និងយុវជន គ្រីស្តបរិស័ទជួបប្រជុំពិភាក្សាគ្នាដើម្បីពង្រឹងជំនឿឱ្យកាន់តែមានភាពរីកចម្រើន

Fevrier-2008.qxd 2/20/2008 11:20 AM Page 8



# អង្គការការីតាស ក្នុងភូមិភាគបាត់ដំបង

ហ៊ូ សុខធារី


Photo : H. Soktheary
កិច្ចប្រជុំរបស់អង្គការការីតាស

កាលពីខែមករា កន្លងទៅនេះ នៅខេត្តពោធិ៍សាត់ អង្គការការីតាស និងក្រុមមេត្តាករុណានៃព្រះសហគមន៍ភូមិភាគបាត់ដំបង មានការប្រជុំមួយ ស្តីពីបញ្ហាក្រីក្រនៅកម្ពុជានៅក្នុងគោលបំណងស្វែងរកយុទ្ធសាស្ត្រ និងសហការរួមគ្នា រវាងអង្គការការីតាស និងព្រះសហគមន៍កាតូលិកលើការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

លោកអភិបាលគីកេ ហ្វីការ៉េដូ អធិបតីនៃអង្គការការីតាសកម្ពុជា បានមានប្រសាសន៍ថា : "អង្គការការីតាសនៅប្រទេសណាក៏ដោយ សុទ្ធចេញពីព្រះសហគមន៍កាតូលិក។ នៅឆ្នាំ១៩៩០ អង្គការការីតាសកម្ពុជា បានប្រសូតឡើង ក្រោមអធិបតីភាពនៃលោកអភិបាលអេមីលដេតម្ប ដែលមានឈ្មោះថា "**Caritas International**"។ លោកក៏បន្តថា ក្នុងនាមជាប្រធាន លោកចង់ឱ្យក្រុមការីតាស និងគណៈកម្មការសង្គហៈព្រះសហគមន៍កាតូលិក រួមបញ្ចូលគ្នាក្នុងគោលដៅជួបប្រជុំ បង្កើតកម្មវិធីដ៏រឹងមាំជាមួយគ្នាដើម្បីបម្រើ និងជួយជនក្រីក្រ។

លោកនុត សំអុល នាយកប្រតិបត្តិអង្គការការីតាសកម្ពុជា បានឱ្យដឹងថា : "អង្គការការីតាសកម្ពុជា ក៏ធ្វើការគាំទ្រ ទៅលើក្រុមមេត្តាករុណានៃព្រះសហគមន៍កាតូលិកដោយស្វែងយល់ពីបញ្ហា និងជួយកាត់បន្ថយភាពក្រីក្រ។ យើងរួមគ្នារិះរកយុទ្ធសាស្ត្រល្អៗ និងរៀបគម្រោងរួបរួមគ្នារវាងក្រុមមេត្តាករុណា និងគណៈកម្មការសង្គហៈ។ លោកក៏បន្ថែមថា ម្នាក់ៗគួរជៀសវាងរកប្រយោជន៍ខ្លួនជាធំ។

កញ្ញាប៉ុល ខាំថងជាសមាជិកក្រុមមេត្តាករុណា និងសង្គមនៃព្រះសហគមន៍កាតូលិក ខេត្តបាត់ដំបង ក៏បានពោលថា : "កិច្ចពិភាក្សារវាងអង្គការការីតាស និងក្រុមមេត្តាករុណាជួយឱ្យខ្ញុំស្គាល់ព្រះសហគមន៍កាតូលិកប្រសើរជាងមុន និងសង្គមផងដែរ ដូចជាបញ្ហាក្រីក្រ ការជួញដូរផ្លូវភេទស្ត្រី និងកុមារ អនក្ខរកម្ម និងភាពអសកម្មខ្លះក្នុងសង្គម-ល-។"

សព្វថ្ងៃនេះ ព្រះសហគមន៍ភូមិភាគបាត់ដំបង មានក្រុមមេត្តាករុណានិងសង្គហៈចំនួន២៦ក្រុម ដោយក្រុមនីមួយៗ គឺមានអ្នកស្ម័គ្រចិត្តចំនួន ១០០នាក់ ដែលមកពីព្រះសហគមន៍កាតូលិកនានា។

## អ៊ឹង ទ្រី : "ព្រះវិញ្ញាណជួយឱ្យខ្ញុំចេះបម្រើបងប្អូនដោយក្តីស្រឡាញ់"

លោកយ៉ូសែបអ៊ឹង ទ្រី ជាប្រធាននៃគណៈកម្មការសង្គហៈនៃព្រះសហគមន៍ផ្សារតូចភ្នំពេញ។ លោកបានចូលរួមបម្រើព្រះសហគមន៍ក្នុងក្រុមសង្គហៈ បន្ទាប់ពីលោកបានទទួលអគ្គសញ្ញាជ្រមុជទឹក នៅ ១៩៩១ នៅជំរំសាយធូ ប្រទេសថៃ។ លោកក៏បានធ្វើមាតុភូមិនិវត្តន៍មកប្រទេសវិញនាឆ្នាំបន្ទាប់។

នៅក្រុងភ្នំពេញ លោកបន្តមុខងារក្នុងក្រុមសង្គហៈទៀតនៅព្រះសហគមន៍ផ្សារតូចនៅក្នុងខែកក្កដា ឆ្នាំ១៩៩៣។ លោកបានបញ្ជាក់ថា : "ព្រះវិញ្ញាណដែលជំរុញឱ្យរូបខ្ញុំចង់បម្រើបងប្អូនដោយចិត្តមេត្តា និងក្តីស្រឡាញ់"។ ម្យ៉ាងទៀត កិច្ចការនេះជួយឱ្យលោកមានជំនឿកាន់តែរឹងមាំឡើងៗ និងមានចិត្តរីករាយដែរ។ ព្រះយេស៊ូក៏ធ្លាប់មានព្រះបន្ទូលថា : "សូមស្រឡាញ់អ្នកដទៃ ឱ្យដូចស្រឡាញ់ខ្លួនឯង"។ ឃ្លានេះដក់ជាប់ក្នុងចិត្តលោកជានិច្ច។ ក្នុងក្រុមនេះ លោកទទួលមុខងារជាអ្នកបើកបររថយន្តជូនអ្នក


Photo : L. Sovanna

ជំងឺដែលមកពីព្រះសហគមន៍កាតូលិកតាមខេត្តទៅមន្ទីរពេទ្យនានា តាមប្រភេទជំងឺ។ រយៈពេលជាង១០ឆ្នាំនេះ លោកប្រាប់ថា មានជួបការលំបាកច្រើនដែរដូចជាជួបអ្នកជំងឺខ្លះគ្មានសំបុត្រអនុញ្ញាតពីព្រះសហគមន៍កាតូលិកដែលគេរស់នៅជាដើម។

លោកយ៉ូសែបអ៊ឹង ទ្រី មានកូន ៤នាក់ ដែល២នាក់ស្ថិតនៅក្នុងបន្ទុក។ បុរសវ័យ ៥៥ឆ្នាំ រូបនេះ ក៏បានបញ្ជាក់ទៀតថា លោកបានចំណាយពេលពេញមួយអាទិត្យសម្រាប់ព្រះសហគមន៍ នៅតែមួយរសៀលថ្ងៃអាទិត្យប៉ុណ្ណោះដែលលោកសម្រាក។ នាថ្ងៃខ្លះពេលមានបុណ្យធំ ក្នុងព្រះសហគមន៍ គឺគ្មានពេលសម្រាកឡើយ។ តែលោកទទួលស្គាល់ថាក្នុងពេលបំពេញការងារ ក៏តែងមានកំហុសឆ្គងខ្លះៗដែរ។








Photo : Ann-Laure Porré
កែង រ៉េង
ញៀម វណ្ណាឫទ្ធិ
ភីរៈ គ្រុយ

# អនាគត គឺធ្វើការងារ

អាន ឡូរ៉ ប៉ូរ៉េ

**ជួបជាមួយយុវជន ៣នាក់ ដែលបានចែករំលែកការពិចារណារបស់ពួកគេអំពីអនាគត។**

**ភីរៈ គ្រុយ អាយុ ២៣ឆ្នាំ និស្សិតទន្តពេទ្យ**

"ក្តីសុបិនរបស់ខ្ញុំ គឺមានគ្លីនិកផ្ទាល់ខ្លួនមួយ។ អ្នកធ្វើការស៊ីប្រាក់ខែអាចរកបានដំបូង ក្នុងរង្វង់ ៥០០ ដុល្លារ ប៉ុន្តែនៅពេលដែលគេក្លាយជាថៅកែខ្លួនឯង គេប្រហែលជាអាចរកបានច្រើនជាងនេះ។ ប្រសិនបើគេចេះចាត់ចែងអាជីវកម្មរបស់ខ្លួន គឺមានដូចជាវិនិច្ឆ័យរោគអ្នកជំងឺ ព្យាបាលពួកគេ វាគ្មានបញ្ហាឡើយ ឧបករណ៍ក៏មិនថ្លៃ ហើយការដកធ្មេញមួយមិនពិបាក ដូចជាការវះកាត់នៅមន្ទីរពេទ្យឡើយ! មានទន្តបណ្ឌិត ៤០០នាក់ទូទាំងប្រទេស សម្រាប់ប្រជាជនជិត ១៤លាននាក់។ ដូច្នេះមានភាពងាយស្រួលណាស់នៅក្នុងការស្វែងរកការងារធ្វើ ម្យ៉ាងគោលបំណងរបស់ខ្ញុំ គឺធ្វើការសន្សំសំចៃដើម្បីមានអាជីវកម្មមួយដើរទន្ទឹមនឹងការងារ ដូចជាការទិញលក់ដី និងលេងតុងទីនជាដើម... ប្រភពចំណូលតែមួយពុំគ្រប់គ្រាន់ឡើយ។ ខ្ញុំគិតថា យើងត្រូវសន្សំសំចៃ និងធ្វើការខ្លាំងក្លាដើម្បីការរស់នៅ។ យើងក៏ត្រូវរៀនអាន រៀនសរសេរ និយាយរួម ត្រូវទទួលការអប់រំឱ្យបានខ្ពង់ខ្ពស់។ សម្រាប់ទៅថ្ងៃអនាគតចំពោះប្រទេសកម្ពុជា គឺវាមានសារៈសំខាន់ណាស់ប្រសិនប្រជាជនទទួលបាននូវការអប់រំ ដែលធ្វើឱ្យការអភិវឌ្ឍន៍មានល្បឿនឆាប់រហ័សដែរ"។

**កែង រ៉េង អាយុ ២១ឆ្នាំ ជាកម្មករ**

"ខ្ញុំមកពីស្រុកគៀនស្វាយ ខេត្តកណ្តាល ដែលនៅទីនោះ ខ្ញុំធ្លាប់ជួយគ្រួសារដាំដំឡូងជ្វា។ ក្រោយមកខ្ញុំបានមកធ្វើការនៅភ្នំពេញនៅក្នុងការដ្ឋានសំណង់មួយ។ ការងារនេះគឺជាការសាកល្បងដ៏ពិតប្រាកដមួយ។ ខ្ញុំរកបាន ៣ដុល្លារ ក្នុងមួយថ្ងៃ។ ខ្ញុំធ្លាប់គិតថាវាជាការងាយស្រួល តែតាមការពិត ជាការងារដ៏ធ្ងន់ធ្ងរ និងនឿយហត់។ នៅខណៈនោះ ខ្ញុំចង់វិលត្រឡប់ទៅកាន់ភូមិកំណើតវិញ ក្រោយពេលដែលខ្ញុំប្រឡងយកបានបណ្ណបើកបរ។ ក្នុងរយៈពេលពីរសប្តាហ៍ និងចំណាយអស់ទឹកប្រាក់ ៧៥ដុល្លារ គេក៏បានបង្រៀនខ្ញុំ ឱ្យចេះបើកបររថយន្តកាំញ៉ុង។ ជាមួយនិងបណ្ណបើកបរនេះ ខ្ញុំអាចធ្វើការឱ្យក្រុមហ៊ុនទឹកបរិសុទ្ធមួយ។ តែអ្វីដែលខ្ញុំចូលចិត្តជាងនេះ និងជាចំណង់ចំនូលចិត្តរបស់ខ្ញុំ គឺខ្ញុំចង់ក្លាយខ្លួនជាអ្នកបើកឡានតាក់ស៊ី ព្រោះវាងាយស្រួល។ ហើយមិនយូរប៉ុន្មាន ខ្ញុំប្រហែលជាអាចមានរថយន្តផ្ទាល់ខ្លួនផងក៏មិនដឹង។ នៅជាមួយនឹងក្រុមមិត្តភ័ក្តរបស់ខ្ញុំ យើងធ្វើការពិភាក្សាជារឿយៗ អំពីបញ្ហា ស្វែងរកប្រាក់ចំណូល។ សម្រាប់ខ្ញុំ ខ្ញុំគ្រាន់តែចង់មានលទ្ធភាពអាចចិញ្ចឹមគ្រួសារ និងមានជីវិតដ៏ថ្លៃថ្នូរ។ តែទោះយ៉ាងណា ចំពោះខ្ញុំក្នុងពេលពី២ ទៅបីឆ្នាំខាងមុខ ខ្ញុំមិនដឹងថា នឹងធ្វើអ្វីទៀតឡើយ ខ្ញុំក៏មិនបានគិតអំពីរឿងគម្រោងនោះនៅឡើយទេ"។

**ញៀម វណ្ណារិទ្ធ អាយុ ២០ឆ្នាំ កសិករ**

"ខ្ញុំទៅរៀននៅឯវិទ្យាល័យ ជារៀងរាល់ថ្ងៃ ដែលមានចម្ងាយ ១៥គីឡូម៉ែត ពីផ្ទះ លើកលែងតែក្នុងរដូវច្រូតកាត់ ដែលនៅពេលនោះ ខ្ញុំត្រូវជួយឪពុកម្តាយរបស់ខ្ញុំធ្វើការនៅក្នុងវាលស្រែ។ ខ្ញុំមិនចង់ឱ្យខ្លួននៅតែជាកសិករដូចលោកឪពុកខ្ញុំទេ។ ការងារនេះមានការនឿយហត់ខ្លាំងណាស់ហើយគេរកបានហូបតែមួយរស់ៗប៉ុណ្ណោះ។ ខ្ញុំចង់ក្លាយខ្លួនជាមគ្គុទេសន៍ទេសចរណ៍ ប្រើប្រាស់ភាសាអង់គ្លេស នៅទីក្រុងសៀមរាប។ ជាមួយនិងមិត្តភ័ក្តនៅពេលដែលយើងនិយាយអំពីរឿងអនាគត យើងនិយាយពីការសិក្សារបស់យើង និងការប្រឡងប្រជែងចូលរៀនមហាវិទ្យាល័យ... អ្នកខ្លះចង់ក្លាយជាគណនេយ្យករ ខ្លះចង់ក្លាយជាគិលានុបដ្ឋាក ឬជាសាស្ត្រាចារ្យទៅតាមសមត្ថភាព និងចំណង់ចំនូលចិត្តគេរៀងៗខ្លួន។ រស់នៅ គ្មានចំណេះដឹង និងប្រសិនបើគេមិនស្រឡាញ់ការងារទៀត គឺមិនអាចទៅរួចទេ។ បើតាមឪពុកម្តាយរបស់ខ្ញុំ ប្រទេសកម្ពុជានឹងមានការអភិវឌ្ឍន៍ដូចជាសហរដ្ឋអាម៉េរិក ប្រទេសជាតិនឹងត្រូវការមនុស្សដែលមាននូវគុណសម្បត្តិគ្រប់គ្រាន់អ៊ីចឹងហើយ! ទើបពួកគាត់ជំរុញលើកទឹកចិត្តខ្ញុំ ឱ្យខិតខំរៀនសូត្រ។ នៅប៉ុន្មានឆ្នាំទៅមុខ ខ្ញុំក៏នឹងគិតរៀបការ បើខ្ញុំមានការងារមួយ និងមានលទ្ធភាពចិញ្ចឹមប្រពន្ធ ខ្ញុំមិនចង់បានអ្វីច្រើនជាងនេះទេ។"

បទយកការណ៍

# ចំណាប់អារម្មណ៍របស់យុវជនលើមណ្ឌលបុប្ផាណា

**អាគីប**



Photos : A Keup / Photos achieve :







**ធ្លាប់ឮ ប៉ុន្តែមិនដែលធ្លាប់បានឃើញ**

សម្រាប់ជាលើកដំបូង ដែលកញ្ញាស្រីគុជ មកកាន់មជ្ឈមណ្ឌលធនធានសោតទស្សន៍"បុប្ផាណា" នេះ។ កញ្ញាហាក់ដូចជាមានភាពចម្លែក នៅក្នុងអារម្មណ៍ ដោយអ្វីៗ ហាក់ដូចជាថ្មីសម្រាប់នាង ព្រោះវាខុសប្លែកពីទីកន្លែងមួយចំនួន ដែលនាងធ្លាប់បានឃើញ ដូចជានៅសារមន្ទីរគុកទួលស្លែង ឬនៅបណ្ណាល័យមួយចំនួនទៀតជាដើម ដោយសារកន្លែងទាំងនោះមានរូបថតជនរងគ្រោះ ហើយនិងភ័ស្តុតាងតិចតួចប៉ុណ្ណោះសម្រាប់ឱ្យទេសចរមើល។ យុវតីវ័យ ២៥ ឆ្នាំរូបនេះបាននិយាយប្រាប់ឱ្យដឹងដែរថា: "អ្វីដែលអស្ចារ្យសម្រាប់ខ្ញុំ គឺនៅទីនេះ ឯកសារភាគច្រើនហាក់នៅថ្មីស្រឡាង ទោះបីជាវាមានអាយុកាលជាច្រើនឆ្នាំកន្លងមកហើយក៏ដោយ"។ ស្រីគុជបន្ថែមថា មជ្ឈមណ្ឌលនេះមានសារសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជា ក៏ដូចជាមនុស្សជាច្រើនទៀត ធ្វើការស្វែងយល់ ពិសេស សម្រាប់អ្នកជំនាន់ក្រោយងាយស្រួលក្នុងការធ្វើការស្រាវជ្រាវ ពីប្រវត្តិសាស្ត្រផ្សេងៗ ដែលទាក់ទងនឹងប្រទេសកម្ពុជា។

នៅជិតនោះដែរ កំពុងអង្គុយសម្លឹងមើលទៅកញ្ចក់កុំព្យូទ័រយ៉ាងយកចិត្តទុកដាក់ ដោយមិនខ្វាយខ្វល់ពីអ្វីដែលកើតមានឡើង នៅជុំវិញខ្លួនរបស់គេនោះ ទឹម តន អាចចាត់ទុកថា ជាទស្សនិកជនមួយរូបនៃមណ្ឌលនេះផងដែរ ដោយសារទឹមតន មកទស្សនានៅទីនេះជាញឹកញាប់។ ទឹមតនបានចំណាយពេលវេលាក្រោយពីការរៀនធ្វើជាងផ្សារ មកទស្សនាពីព្រឹត្តិការណ៍និងឯកសារសំខាន់ៗមួយចំនួន ដែលគេធ្លាប់បានឮ ប៉ុន្តែមិនដែលបានឃើញ។ ទឹម តន បានដកប្រដាប់ស្តាប់សំឡេងចេញពីត្រចៀក រួចក៏ងាកមកនិយាយឱ្យដឹងថា : "ខ្ញុំមកទីនេះចំនួន៣-៤ដង ហើយ ចាប់តាំងតែពីខ្ញុំដឹងថា នៅទីនេះ មានរឿង និងឯកសារល្អៗ និយាយអំពីប្រវត្តិសាស្ត្រខ្មែរ និងប្រវត្តិអ្នកដឹកនាំខ្មែរនៅតាមសម័យកាលមួយចំនួនទៀតជាច្រើន"។ តនបន្តថា លោកយាយ និងឪពុកម្តាយរបស់គាត់ តែងតែនិយាយប្រាប់ពីខ្មែរក្រហមឱ្យស្តាប់ជារឿយៗ។ "ខ្ញុំធ្លាប់ឮថា ប៉ុលពតធ្វើបាបប្រជាជនយ៉ាងខ្លាំង និងមានមនុស្សច្រើន បានស្លាប់នៅពេលនោះដែរ។ ដូច្នេះខ្ញុំចង់ឃើញមុខគាត់"។



មជ្ឈមណ្ឌលបុប្ផាណា

## លោកប៉ាន់ ឫទ្ធី ផលិតករភាពយន្តខ្មែរដ៏ចំណាន

លោកប៉ាន់ ឫទ្ធីមានស្រុកកំណើតនៅភ្នំពេញ។ លោកកើតនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦៤។ គ្រួសាររបស់លោក និងអ្នកឯទៀតត្រូវបានបណ្តេញចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ដោយពួកខ្មែរក្រហម។ នៅពេលដែលលោកមានអាយុ១៥ឆ្នាំ នាឆ្នាំ១៩៧៩ លោកបានគេចខ្លួនទៅព្រំដែនប្រទេសថៃ ហើយបានធ្វើដំណើរទៅដល់ប្រទេសបារាំង និងរស់នៅទីនោះ។ នៅឆ្នាំ១៩៨៥ លោកបានចូលក្នុងសាលាភាពយន្តជាតិនៃប្រទេសបារាំង។ នៅឆ្នាំ១៩៨៨ លោកបានទទួលពានរង្វាន់លើស្នាដៃភាពយន្តឯកសារលើកដំបូងរបស់លោក និងក្រោយមកទៀត លោកបានទទួលជោគជ័យ និងពានរង្វាន់ជាបន្តបន្ទាប់។ សោកនាដកម្មរបស់ប្រជាជនកម្ពុជាត្រូវបានលេចចេញជារូបរាងឡើងនៅក្នុងឯកសារបោះពុម្ពជាច្រើនរបស់ផលិតករប៉ាន់ ឫទ្ធី។

ឆ្លៀតឱកាសនោះដែរកញ្ញាស្រីគុជ បានកាត់សំដីតនថា នៅក្នុងមណ្ឌលនេះគួរតែមានសៀវភៅឯកសារឱ្យបានច្រើនជាងនេះ សម្រាប់សិស្ស-និស្សិតអាចខ្ចីយកទៅធ្វើការសិក្សាបន្ថែម។ អ្នកទស្សនារូបនេះបានសង្កត់ធ្ងន់ បន្ថែមទៀតថា : "ចំនុចដែលខ្ញុំចាប់អារម្មណ៍ នៅខណៈដែលខ្ញុំមកនេះ គឺឯកសារដែលនិយាយអំពីជីវិតរបស់ប្រជាជនខ្មែរ រស់នៅក្នុងជំរំដែលធ្វើឱ្យខ្ញុំហាក់មានអារម្មណ៍ពិបាកជំនួសពួកគេដោយសារតែកន្លែងពួកគេរស់នៅនោះហ៊ុមព័ទ្ធទៅដោយចំការមីនមីរដេរដាស។"

"ទុក្ខភ័យនៃកែម និងនិត" ជាចំណងជើងភាពយន្តខ្មែរ ដែលកំពុងត្រូវបានអង្គុយសម្លឹង និងតាមដានយ៉ាងជក់ចិត្ត និងជិតអារម្មណ៍ពីសំណាក់ មាស វ៉ាន់ ដោយមិនងាកទៅរកនរណាម្នាក់ ក៏ដូចជាមិត្តភក្តិរបស់គេដែលកំពុងតែអង្គុយនៅក្បែរនោះឡើយ។ នេះគឺជាលើកទី១ របស់វ៉ាន់ដែលបានមកចូលមើលនៅទីនេះ ហើយលើកដំបូងនេះដែរ កុមារីវ័យ១៤ ឆ្នាំរូបនេះ ហាក់មានគំនិតដូច មនុស្សវ័យជំទង់ដែរ ដោយគេគិតថា ឯកសារក៏ដូចជារឿងទាំងអស់នេះមានអត្ថប្រយោជន៏ច្រើនណាស់សម្រាប់អ្នកដែលពុំធ្លាប់បានឃើញ ជាពិសេសក្មេងដូចជារូបគេ។

អ្នកទស្សនាមួយរូបសុំមិនបញ្ចេញឈ្មោះ បានមានប្រសាសន៏ឱ្យដឹងផងដែរថា : "នេះគឺអស្ចារ្យណាស់សម្រាប់ខ្ញុំ ដែលហាក់បានទៅកាន់ពិភពមួយ ដែលខ្ញុំធ្លាប់តែបានឮ តែមិនដែលបានឃើញ។ នេះក៏ជាលើកទី១ ដែលខ្ញុំបានមកទស្សនាមជ្ឈមណ្ឌលធនធានសោតទស្សន៏បុប្ផាណានេះ។ មណ្ឌលនេះ គឺមិនមែនគ្រាន់តែជាកន្លែងកំសាន្ត សម្រាប់ទស្សនារូបភាព ក៏ដូចជាវីដេអូ ដែលមានវ័យចំណាស់នោះទេ ប៉ុន្តែហាក់បីដូចជាមាគ៌ាមួយ ដែលនាំផ្លូវមនុស្សជាច្រើន ជាពិសេសសម្រាប់យុវវ័យ និងមនុស្សជំនាន់ក្រោយ ឱ្យស្គាល់ពីអ្វីដែលបានដើរហួសទៅហើយ តែនៅតែមានស្នាមជាប់ជិតដាមក្នុងក្រអៅបេះដូងរបស់ប្រជាជនកម្ពុជាជារៀងរហូត"។

កញ្ញាជុំ ណយ ជាអ្នកវិភាគឯកសារនៃមជ្ឈមណ្ឌលធនធានសោតទស្សន៏ បុប្ផាណា បានមានប្រសាសន៏ឱ្យដឹងថា: "គោលដៅនៃមជ្ឈមណ្ឌលនេះ គឺចង់ធ្វើឱ្យឯកសារដែលជាបេតិកភណ្ឌសោតទស្សន៏ដែលមានវ័យចំណាស់ៗ មានភាពរស់រវើកឡើងវិញ"។ កញ្ញាបន្ថែមថា កាលណាយើងមកទីនេះយើងអាចឃើញឯកសារដែលកើតមានឡើងនៅតាមសម័យកាលនីមួយៗ ពិតៗតែម្តង ដែលវាធ្វើឱ្យយើងអាចពិចារណារកឃើញនូវអ្វីដែលល្អ អ្វីដែលអាក្រក់និងរវាងភាពស-ខ្មៅជាដើម។ ម្យ៉ាងទៀតអ្នកទស្សនា ក៏អាចធ្វើការសិក្សាបង្កើនចំណេះដឹង ពីឯកសារទាំងនោះបានយ៉ាងច្រើនទៀតផងដែរ។

***"ធ្វើឱ្យឯកសារដែលជាបេតិកភណ្ឌសោតទស្សន៏ដែលមានវ័យចំណាស់នោះឱ្យមានភាពរស់រវើកឡើងវិញ"***

**តើមជ្ឈមណ្ឌលធនធានសោតទស្សន៏ "បុប្ផាណា" មានបង្កប់អ្វីខ្លះ ?**

មជ្ឈមណ្ឌលធនធានសោតទស្សន៏ បុប្ផាណា ឬដែលមនុស្សភាគច្រើន ហៅថា "មណ្ឌលបុប្ផាណា" បានចាប់ផ្តើមប្រមូលឯកសារដែលទាក់ទងនឹងប្រទេសកម្ពុជា ដែលបានបាត់បង់ស្ទើរតែទាំងស្រុង តាំងពីនៅដើមឆ្នាំ២០០៥។ មជ្ឈមណ្ឌលនេះត្រូវបានដាក់សម្ពោធឱ្យចូលទស្សនាជាសាធារណៈ នាដើមខែធ្នូ ឆ្នាំ២០០៦ ដោយមានសមាគមពីរ រួមសហការគ្នា គឺសមាគម **AADAC** នៅប្រទេសបារាំង ដែលជាសមាគមជួយការអភិវឌ្ឍន៏លើវិស័យសោតទស្សន៏នៅកម្ពុជា និងសមាគម **ARPAA** នៅប្រទេសកម្ពុជា ដែលជាសមាគមដើម្បីស្រាវជ្រាវផលិតនិងថែរក្សាឯកសារសោតទស្សន៏នានា។

សព្វថ្ងៃនេះ មជ្ឈមណ្ឌល បុប្ផាណា មានផ្ទុកឯកសារដែលមានប្រភពផ្សេងៗគ្នា គឺដូចជា មកពីប្រទេសបារាំង និងពីកម្ពុជា ដែលមានគ្រប់ប្រធានបទទាំងអស់ គឺដូចជា ប្រវត្តិសាស្ត្រ សិល្បៈ ប្រពៃណី សុខភាព បរិស្ថាន សាសនា ឬនយោបាយ...។ អ្នកនាងថន ថាណារ៉ែន អ្នកវិភាគឯកសារក្នុងមជ្ឈមណ្ឌលធនធានសោតទស្សន៏បុប្ផាណា មានប្រសាសន៏ថា : "អ្នកទស្សនាភាគច្រើន ចង់ដឹង ចង់ឃើញពីហេតុការណ៍ ដែលកើតមានឡើង នាសម័យខ្មែរក្រហម និងមួយចំនួនទៀតមើលពីសិល្បៈ ដែលមានដូចជារបាំព្រះរាជទ្រព្យ របាំអប្សរា និងព្រះច័ន្ទគោរពជាដើម ដែលមានតាំងពីឆ្នាំ១៩២០។ ខ្លះចង់ឃើញពីឯកសារបរិស្ថាន ដែលមានបង្ហាញអំពីទិដ្ឋភាពបឹងទន្លេសាប (ពី១៩៣០-បច្ចុប្បន្ន) ការនេសាទ ការថែរក្សាព្រៃឈើរបស់ជនជាតិភាគតិច (២០០៥-២០០៧)។ ណារ៉ែនបញ្ជាក់ថា អ្នកមកទីនេះគឺមានវ័យខុសៗគ្នា គឺមានតាំងពីក្មេងៗអាយុពី១៤-១៦ ឆ្នាំ សិស្ស-និស្សិត និងយុវវ័យជាដើម។ បណ្ណាសារទាំងនេះមានប្រភពមកពីទីកន្លែងផ្សេងៗគ្នា ដូចជាតាមស្ថានីយ៏ទូរទស្សន៏ ស្ថានីយ៏វិទ្យុ ផលិតករឯករាជ្យ ស្ថាប័ន (ក្រសួង ឬអង្គការក្រៅរដ្ឋាភិបាល) និងផ្នែកឯកជននានាជាច្រើនទៀត។ រីឯអ្នកវិភាគឯកសារនៃមជ្ឈមណ្ឌលដ៏មានអត្ថប្រយោជន៏នេះក៏បានមានប្រសាសន៏ឱ្យដឹងបន្ថែម ពីប្រព័ន្ធផ្ទុកទិន្នន័យនៃមណ្ឌលនេះផងថា មូលដ្ឋានផ្ទុកទិន្នន័យនៅទីនេះមានឈ្មោះថា "ហនុមាន" ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ ហើយអ្នកប្រើប្រាស់ អាចជ្រើសរើសមើលបានបីភាសា គឺមានភាសាខ្មែរ អង់គ្លេស និងបារាំង។ មូលដ្ឋានទិន្នន័យនេះផ្តល់លទ្ធភាពទៅកាន់សាធារណជន អាចជ្រើសរើសឯកសារ ហើយអាចទស្សនានូវឯកសារទាំងនោះបានភ្លាមៗតែម្តងតាមរយៈរបៀបស្រាវជ្រាវរកឯកសារខុសៗគ្នា។

**ហេតុអ្វីដាក់ឈ្មោះថា "បុប្ផាណា"**

"បុប្ផាណា" គឺជាឈ្មោះរបស់អ្នកទោសស្ត្រីខ្មែរមួយរូប ដែលមានវ័យ ២៥ឆ្នាំ និងត្រូវគេធ្វើបាបនៅក្នុងសារមន្ទីរស២១ ហើយគាត់មានភាពក្លាហានហ៊ានតស៊ូ សម្រាប់ភាពលំបាកលំបិន នៅក្នុងសម័យខ្មែរក្រហមនោះ។ ដោយគិតទៅដល់ឈ្មោះ"បុប្ផាណា" នេះ មជ្ឈមណ្ឌលធនធានសោតទស្សន៏នេះ ចង់ប្រែក្លាយខ្លួនឯងឱ្យទៅជាអ្នកពាំនាំពាក្យពេចន៏ នៃការតស៊ូ សេចក្តីក្លាហាន និងឧត្តមភាព ដែលអ្នកទោសស្ត្រីរូបនេះបានបន្សល់ទុកឱ្យយើងរាល់គ្នា។

**មជ្ឈមណ្ឌលបុប្ផាណា**

ស្ថិតនៅផ្ទះ ៦៤ ផ្លូវ ២០០ ឧកញ៉ាម៉ែន ភ្នំពេញ។ អគារមជ្ឈមណ្ឌលនេះត្រូវបានប្រគល់ឱ្យប្រើប្រាស់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ មជ្ឈមណ្ឌលគ្រោងបង្កើតនូវវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈខាងផ្នែកសោតទស្សន៏ និងផ្នែកភាពយន្ត ដើម្បីជួយបំផុសឱ្យមានការផលិតភាពយន្តគុណភាពនៅក្នុងប្រទេស។ ដោយសារមានការជួយបង្ហាត់បង្រៀនពីក្រុមអ្នកបណ្តុះបណ្តាលដែលមានជំនាញ។ វគ្គបណ្តុះបណ្តាលនេះ នឹងផ្តោតជាសំខាន់ទៅលើការងារអនុវត្តន៏ដោយផ្ទាល់ ដើម្បីផលិតឯកសារវីដេអូ វិទ្យុ ឬរូបថត ដែលនិយាយអំពីសង្គមកម្ពុជា ឱ្យស្របទៅតាមលក្ខណៈប្រពៃណី និងការវិវត្តនៃភាពទំនើបរបស់ប្រទេសជាតិ។ ទូរស័ព្ទទំនាក់ទំនងមជ្ឈមណ្ឌល : 023 992 174។

Website : www.bophana.org

Fevrier-2008.qxd 2/20/2008 11:21 AM Page 12

## កសិកម្ម

# កៅស៊ូជាដំណាំឧស្សាហកម្មសំខាន់

ជាត សំភី


Photos: CEDAC

តាមប្រសាសន៍របស់លោកអ៊ី កាឌុំ ជាអ្នកឯកទេសសហគមន៍នៃអង្គការសេដាក បានឱ្យដឹងថា :

កៅស៊ូជារុក្ខជាតិព្រៃ ដែលចាប់កំណើតនៅប្រទេសប្រេស៊ីល នៅព្រៃអាម៉ាហ្សូន ក្រោយមកនៅជំនាន់អាណានិគមនិយមបារាំង គេបានយកមកដាំលើកដំបូង នៅក្រុងព្រះសីហនុ ក្រោយមកសាយភាយទៅដល់ខេត្តកំពង់ចាម និងខេត្តផ្សេងៗទៀត នៅប្រទេសកម្ពុជា។ កៅស៊ូមានសារៈប្រយោជន៍ច្រើនយ៉ាង ដូចជាយកជ័រ ធ្វើគ្រឿងសង្ហារិម ពោះវៀន-សំបកកង់ ស្រោមដៃកៅស៊ូ ឬធ្វើអុស-ល-។

ការដាំដុះកៅស៊ូ គេនិយមធ្វើនៅលើដីក្រហម ប៉ុន្តែគេក៏អាចដាំដុះ នៅលើប្រភេទដីសផងដែរ ប្រសិនបើដីនោះនៅតំបន់ខ្ពស់រាបពុំជាំទឹក។ ទោះជាយ៉ាងណាកៅស៊ូដែលដាំដុះនៅលើដីសដីល្បាយ មិនមានកំហាប់ជាតិជ័រច្រើនដូចដាំលើដីក្រហមទេ។ កៅស៊ូមានច្រើនពូជណាស់ គឺដូចជា ពូជ**CT1** ពូជរីម និងពូជវ៉េវនាំចូលពីវៀតណាម។ កសិករដែលចង់ដាំ ក៏អាចស្វែងរកពូជពីវិទ្យាស្ថានកៅស៊ូកម្ពុជាបាន។

**ក. របៀបដាំ :** រណ្តៅត្រូវកាប់ទំហំ ៤០x៤០x៤០សម។ សូមកាយអាចម៍ដីស្រទាប់លើដាក់នៅមួយចំហៀង និងអាចម៍ដីស្រទាប់ក្រោម មួយចំហៀងទៀត។ កាត់បាតថង់កូនកម្រាស់ ២សមដើម្បីយកចុងឫសកែវខ្សៀនចេញ។ ចូរដាក់កូនកៅស៊ូទៅក្នុងរណ្តៅដាក់បែរមុខបំបៅទៅទិសនិរតី យកកាំបិតវះចំហៀងថង់រួចលាត់ឡើងបន្តិចម្តងៗ ទន្ទឹមនឹងការលប់ដីចូលរណ្តៅ ត្រូវជាន់បង្ហាប់ឱ្យណែនយ៉ាងតិច៣ដង។ អាចម៍ដីលប់រណ្តៅ គឺត្រូវយកស្រទាប់លើលប់មុន ហើយស្រទាប់ក្រោមលប់ពីលើ ដោយទុកឱ្យនៅរាងថ្ពក់ទឹកមាត់រណ្តៅបន្តិច និងលៃឱ្យភ្នែកបំបៅ លេចចេញផុតពីទីរ៉ូដីប្រហែល ៣សម។ នៅពេលដាំគេដាក់ជី **N.P.K** ដើម្បីទ្រាប់បាត។

**ខ. កាត់ខ្នែង :** កៅស៊ូត្រូវការដើមត្រង់ ដើម្បីយកជ័រ។ ហេតុនេះចាំបាច់យើងត្រូវធ្វើការកាត់ខ្នែងដុះចេញពីដើមឱ្យបានស្អាត យ៉ាងហោចណាស់ឱ្យបានកម្ពស់ពី២,៥ទៅ៣សម ពីដីដែរ។ ផ្ទុយទៅវិញការលះខ្នែងខ្ពស់ពេក ធ្វើឱ្យដើមកៅស៊ូវៀវក្រធំ។

ដាំកៅស៊ូមិនមែនជាការងាយស្រួលនោះទេ គឺត្រូវតែចេះថែរក្សារយៈពេលពី៥ឆ្នាំ ទៅ៥ឆ្នាំកន្លះ ទើបកៅស៊ូអាចជៀជ័របាន។ ក្នុងនោះ បច្ចេកទេសក្នុងការប្រើប្រាស់ជី ការពារ និងព្យាបាលជំងឺកៅស៊ូ ក៏មានសារៈសំខាន់ផងដែរ ដូច្នេះទាល់តែកសិករទៅសិក្សាពីអ្នកបច្ចេកទេសជំនាញបន្ថែមទើបបាន។

## បរិស្ថាន

### ស្ថានភាពបឹងទន្លេសាប

បឹងទន្លេសាប គឺជាបឹងទឹកសាបដ៏ធំបំផុត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងស្ថិត នៅតំបន់វាលទំនាបកណ្តាលនៃប្រទេសកម្ពុជា។ បឹងទន្លេសាបបានកកើតជាង៥000ឆ្នាំមកហើយ។ របបទឹកបឹងទន្លេសាបមានលក្ខណៈទៀងទាត់ គឺនៅរដូវវស្សា ទឹកហូរពីទន្លេមេគង្គ ទៅកាន់បឹងទន្លេសាប ដែលធ្វើឱ្យកម្រិតទឹកឡើងខ្ពស់ពី១ម៉ែត្រ ទៅ៨-៩ម៉ែត្រ ហើយផ្ទៃបឹងមានទំហំធំជាងមុន គឺពី២៥00 ទៅ១0000គីឡូម៉ែត្រការ៉េ ដែលអាចផ្ទុកទឹកបានពី ១,៣ ទៅ៧0 កោដិម៉ែត្រគូប។


Photos: DR

របបទឹកបឹងទន្លេសាប ក៏ជួយឱ្យមានលំនឹងប្រព័ន្ធអេកូឡូស៊ី និងមច្ឆាជាតិក្នុងបឹងធម្មជាតិនេះ ដែលរួមមានត្រី សហគមន៍ព្រៃឈើ និងសត្វព្រៃ ដែលជាប្រភពធនធានដ៏សំខាន់ សម្រាប់សេដ្ឋកិច្ចរបស់ប្រជាជន។ ប្រជាជនកម្ពុជាជាងពាក់កណ្តាល ពឹងពាក់ទៅលើធនធាននៃបឹងទន្លេសាបនេះ។ កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចជាផ្លូវការ ប្រែក្លាយបឹងទន្លេសាបរបស់កម្ពុជាឱ្យទៅជាតំបន់អភិរក្សធនធានធម្មជាតិ កាលពីខែតុលា នាឆ្នាំ១៩៩៧ ដែលវាស្ថិតនៅក្រោមកម្មវិធីអភិរក្សធនធានធម្មជាតិរបស់អង្គការយូណេស្កូ។

បឹងទន្លេសាបត្រូវបានបែងចែកជាបីតំបន់ធំៗ គឺតំបន់ស្នូល តំបន់ការការពារ និងតំបន់ទ្រនាប់។ តំបន់ទាំងបីនេះមានប្រព័ន្ធអេកូឡូស៊ីយ៉ាងសំខាន់ក្នុងការទទួលបានការអភិរក្ស និងថែរក្សា។ រីឯតំបន់ទទួលការការពារវិញ គឺជាតំបន់ព្រៃលិចទឹក ដែលជាជម្រកត្រីពង។ ចំណែកតំបន់ទីបីវិញនោះ គឺជាដីសម្រាប់ប្រជាកសិករធ្វើកសិកម្ម។

**ប្រែសម្រួលដោយ ថុង យ៉ត**



## សុខភាព

# ទឹកដោះជាអាហារសំខាន់

ជាត សំភី


Photo: L. Sovanna

បើតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិត ដុក ហម ឯកទេសខាងរោគកុមារ បានឱ្យដឹងថា :

ទឹកដោះម្តាយដំបូងមានសារៈសំខាន់ណាស់ ព្រោះវាសម្បូរទៅដោយសារធាតុអាហារនានា និងភាពស៊ាំដែលម្តាយផ្តល់ឱ្យកូន។ ដូច្នេះការដែលចាស់ៗឱ្យអ៊ុំៗកូនបៅជំនួសជាប្រការមួយខុសឆ្គង។

លោកវេជ្ជបណ្ឌិត ក៏បន្តទៀតថា អ្នកម្តាយគួរតែឱ្យកូនតូចបៅទឹកដោះសុទ្ធរហូតមានអាយុ ៦ខែ ទើបបន្ថែមអាហារូបត្ថម្ភដល់គេ។ ទោះបី អ្នកម្តាយខ្លះយល់ថា ទឹកដោះរបស់គាត់មិនគ្រប់គ្រាន់ ប៉ុន្តែទឹកដោះម្តាយគឺគ្រប់គ្រាន់ណាស់ ព្រោះពេលកូនជញ្ជក់កាន់តែខ្លាំង ទឹកដោះចេញកាន់តែច្រើន។ ប៉ុន្តែនេះពុំមែនមានន័យថា មិនឱ្យកូនផឹកទឹកសោះនោះទេ ដូចនៅពេលដែលកូនមានរាគខ្លាំង រហូតដល់ខ្សោះជាតិទឹក អ្នកម្តាយទាំងឡាយក៏អាចឱ្យកូនអឹមសិនរួចទើបបន្ថែមទឹកអូរ៉ាលីតតាមក្រោយ។

ចំណែកវិធីសាស្ត្រនៃការបំបៅកូន គឺអ្នកម្តាយត្រូវបំបៅកូននៅដោះម្ខាងឱ្យអស់ សឹមដូរទៅកាន់ដោះម្ខាងទៀត ហើយកូនត្រូវដាក់នៅក្នុងទីតាំងឱ្យបានល្អ កុំឱ្យកូនរមួលក និងឱ្យកូនបៅឱ្យស៊ប់ល្អ។

ការបំបៅកូន ត្រូវធ្វើឡើងរហូតដល់ កូនមានអាយុ ៦ខែ ទើបរកអាហារូបត្ថម្ភដល់កូនបន្ថែម ក្រោម៦ខែ ពុំអាចបន្ថែមអាហារូបត្ថម្ភបានទេ ព្រោះក្រពះកូនមិនទាន់ទុំ។ អាហារូបត្ថម្ភមិនចាំបាច់មានច្រើនទេ គឺអាចរកបាននៅក្នុងមូលដ្ឋាន មានដូចជា បន្លែពណ៌លឿង ខៀវ ក្រហម ឬស៊ុត-ល- សុទ្ធតែមានសារៈប្រយោជន៍។ ការបំបៅដោះកូន ត្រូវធ្វើឡើងរហូតដល់កូនអាយុ ២ឆ្នាំ ឬលើសពីនេះ ហើយមិនប្រកាន់ថា កូនប្រុស ឬស្រី ឡើយ។

និយាយរួម លោកវេជ្ជបណ្ឌិតដុក ហម បានធ្វើការផ្តាំផ្ញើទៅកាន់មាតាថា ការបំបៅដោះកូន គឺវាមានសារៈសំខាន់ណាស់ ទីមួយ គឺវាបានរឹតចំណងមេត្រីភាព និងមនោសញ្ចេតនារវាងម្តាយ និងកូន។ ទីពីរ ទោះបីទឹកដោះគោល្អ យ៉ាងណាក៏គ្មានភាពស៊ាំ និងសារធាតុអាហារដូចក្នុងទឹកដោះម្តាយដែរ។ ហើយទីបី ដោះម្តាយប្រៀបដូចជារោងចក្រដែលផលិតទឹកដោះមិនចំណាយសោហ៊ុយគ្រាន់តែលាងទឹកឱ្យស្អាតទៅបានហើយ( មិនត្រូវលាងសាប៊ូទេ) ព្រោះវាធ្វើឱ្យបាត់ក្លិនធម្មជាតិសម្រាប់កូនតូច។

### ៤២៤នាក់ ស្លាប់ដោយគ្រុនឈាម

ជំងឺគ្រុនឈាមជាជំងឺមួយដ៏កាចសាហាវ និងសម្លាប់កុមារកម្ពុជាអស់ជាច្រើននាក់ក្នុងមួយឆ្នាំៗ។ ជំងឺនេះឆ្លងតាមរយៈមូសខ្លាខ្វាំ ជាពិសេសនៅពេលថ្ងៃ។ ប្រភពចម្លងរបស់មូសខ្លា គឺកើតឡើងពីដង្កូវទឹកមូសខ្លា ដែលរស់នៅក្នុងទឹកដក់កង្វក់នៅក្នុងសំបកកំប៉ុង សំបកដប សំបកកង់ ឡាន ទឹកថ្លុក... នៅជុំវិញបរិវេណផ្ទះ។ នៅឆ្នាំ២០០៧ ព្រះរាជា-ណាចក្រកម្ពុជាត្រូវបានប្រឈមមុខនឹងការឆ្លងរាតត្បាតនៃជំងឺគ្រុនឈាមដ៏អាក្រក់។

ជាសរុប កុមារ៤០៧នាក់ បានស្លាប់បន្ទាប់ពីបានទទួលការចម្លងជំងឺនេះ និងមានកុមារ ៤០០០០នាក់ បានឆ្លងជំងឺគ្រុនឈាម។ នៅដើមឆ្នាំ១៩៩៨ ជំងឺគ្រុនឈាមនេះបានសម្លាប់កុមារអស់ជាច្រើនដោយមានកុមារ ៤២៤នាក់បានស្លាប់។ ប៉ុន្តែចំនួនសរុបនៃករណីចម្លងមានទំហំតិចតួចជាង គឺ១៦០០០នាក់។

**អ្នកនាំសារ**

# រលាកបំពង់ក


Photo: P. Samphy

លោកវេជ្ជបណ្ឌិតទេព សោភ័ណ្ឌ ឯកទេសត្រចៀកច្រមុះ និងបំពង់ក នៃមន្ទីរពេទ្យព្រះកេតុមាលា បានមានប្រសាសន៍ឱ្យដឹងដែរថា រលាកបំពង់កគឺជាជំងឺមួយដែលច្រើនតែកើតនារដូវធ្លាក់ខ្យល់ ព្រោះរដូវនេះធ្វើឱ្យយើងផ្តាសាយ ហើយកាលណាយើងមានការយឺតយ៉ាវធ្វើការព្យាបាល បណ្តាលឱ្យផ្តាសាយកាន់តែខ្លាំងឡើង សំបោរធ្លាក់ចូលមាត់ ដែលធ្វើឱ្យបំពង់ករលាក។ មួយទៀតជំងឺរលាកបំពង់កនេះក៏កើតឡើងដោយសារយើងមិនបានថែខ្លួន គឺចេះតែញ៉ាំទឹកកក ឬក៏ភេសជ្ជៈក្លាសេដែលត្រជាក់ខ្លាំង ធ្វើឱ្យកោសិកាបំពង់កត្រជាក់ខ្លាំង ទទួលការរលាក។ ហើយពួកវីរុសអាចធ្វើឱ្យរលាកបំពង់កដែរ។ រោគសញ្ញារលាកបំពង់ក មានក្តៅខ្លួន ហៀរសំបោរ រួចមានក្អក តឹងច្រមុះ គឺរោគសញ្ញាដូចផ្តាសាយដែរ។ បើមានរលាកបំពង់ក គឺអ្នកជំងឺត្រូវតមញ៉ាំទឹកកក ឬភេសជ្ជៈក្លាសេ។ បន្ទាប់មកគាត់ត្រូវទៅស្វែងរកលោកគ្រូពេទ្យជំនាញ ដើម្បីឱ្យពិនិត្យមើលបំពង់ក ដើម្បីទទួលការពិនិត្យតាមរោគសញ្ញា និងព្យាបាលដោយថ្នាំ។ លោកគ្រូពេទ្យនឹងឱ្យថ្នាំដូចជាពួកសេ-វ៉ាទីស ប៉ារ៉ាសេតាមុល វីតាមីនសេ ឬថ្នាំផ្សះ។ បើនិយាយរួមគឺមានតែគ្រូពេទ្យជំនាញទេ ដែលអាចពិនិត្យ និងព្យាបាល ទៅតាមរោគសញ្ញារបស់អ្នកជំងឺម្នាក់ៗ។ បន្ទាប់មកអ្នកជំងឺត្រូវសម្រាក ឱ្យបានគ្រប់គ្រាន់ និងបរិភោគអាហារឱ្យបានសមរម្យ។

លោកវេជ្ជបណ្ឌិតបានធ្វើការផ្តាំផ្ញើដល់ប្រជាពលរដ្ឋទាំងអស់ឱ្យចេះបង្ការខ្លួនអំពីជំងឺរលាកបំពង់ក ដូចជា បើខែធ្លាក់ខ្យល់ យើងត្រូវដាំទឹកក្តៅមុជ និងកុំញ៉ាំភេសជ្ជៈដែលក្លាសេ ឬញ៉ាំទឹកកក ហើយយើងត្រូវសម្រាកឱ្យបានទៀងទាត់ពេលវេលាផងដែរ។ សូមបញ្ជាក់ថា ជំងឺរលាកបំពង់កកើតលើគ្រប់វ័យទាំងអស់ តែភាគច្រើនកើតលើវ័យដែលកំពុងលូតលាស់ជាពិសេសលើកូនក្មេង រីឯមនុស្សចាស់ អាយុចាប់ពី៤៥ឆ្នាំ ឡើងទៅ មិនសូវជាជួបប្រទះទេ។

Fevrier-2008.qxd 2/20/2008 11:21 AM Page 14

## ប្រពៃណី



Photo : DR

# អាយ៉ៃ មរតកវប្បធម៌ជាតិខ្មែរដ៏ពេញនិយម

### អាគីប និងសម្ផស្ស

អាយ៉ៃ គឺជាសិល្បៈបុរាណខ្មែរមួយ ដែលមានតាំងពីយូរយារណាស់មកហើយ ។ គេនិយមលេងនៅតាមពិធីបុណ្យផ្សេងៗ និងពិធីអាពាហ៍ពិពាហ៍ផងដែរ ។

អ្នកស្រីអ៊ុក សុផា ជាអ្នកចម្រៀងអាយ៉ៃបុរាណតាំងតែពី ឆ្នាំ១៩៧២មក បានមានប្រសាសន៍ថា : "ការច្រៀងអាយ៉ៃ គឺមានការលំបាកច្រើនជាងសិល្បៈដទៃ ដោយ-សារតែចម្រៀងបុរាណ-សម័យ ល្ខោន ឬយីកេ មានទំនុកច្រៀងរួចជាស្រេច ដោយឡែក សម្រាប់ចម្រៀងអាយ៉ៃ គឺមិនមានទំនុកច្រៀងទេ" ។ អ្នកស្រីបានបន្តថា អ្នកចម្រៀងអាយ៉ៃ តម្រូវឱ្យចេះសម្ដែង ស្ទើរតែទាំងអស់ ដូចជាសម្ដែងតួកាច តួស្លូត តួសប្បាយ តួឡិះឡក់ ឬតួកំប្លែងជាដើម ។ ការច្រៀងអាយ៉ៃ មានច្រើនដំណាក់កាល ដូចជា ដំបូង ត្រូវច្រៀងទាក់ទាញភ្ញៀវឱ្យមានការសើចសប្បាយ តែជាមួយគ្នានោះដែរ អ្នកចម្រៀងក៏មិនត្រូវភ្លេចបញ្ចូលនូវអត្ថន័យខ្លឹមសារនៃប្រធានបទ ដែលយើងច្រៀងនៅក្នុងនោះឡើយ ។

អ្នកស្រី បានឱ្យដឹងដែរថា ចម្រៀងអាយ៉ៃមានជាង១០បទ ។ អ្នកច្រៀងត្រូវបញ្ចូលបទទាំងនេះជាមួយគ្នាតាមដំណើរនីមួយៗ ដូចជា ពីដំបូង គេច្រៀងបទពាក្យ៧ ដែលគេហៅថា "បទនមសការ" ដើម្បីធ្វើជាការរំឭកគុណ ។ បន្ទាប់មក "បទបំពេរក្លាយ" ដើម្បីធ្វើការគោរពដល់ញាតិមិត្តជិតឆ្ងាយ និងអញ្ជើញខាងស្រីឱ្យចេញមក ។ ក្រោយមកច្រៀង "បទកេមចារ" ដែលគេច្រៀងប្រទាក់ប្រទងគ្នាទៅវិញទៅមក ។ រួចមកខាងស្រីត្រូវការសួរទៅខាងប្រុសពីខ្លឹម-សារលើប្រធានបទដោយច្រៀង "បទឱលឡា" ដែលច្រៀងរបៀបជារយាលបន្តិច ។ នៅពេលចប់អំពីការរៀបរាប់ប្រវត្តិហើយ អ្នកទាំងពីរចាប់ផ្ដើមធ្វើការលាគ្នា ដោយច្រៀងជា "បទការ៉េយ៉ាន់សា" ។ វគ្គបញ្ចប់នេះ មានច្រើនបទដែលអ្នកចម្រៀងអាចច្រៀងបាន គឺដូចជា "បទភ្ញុំភ្នួង ឬសោយសង្វាន ឬសែនស្រណោះ ឬចាប់ផ្ទៃ" ។

ចម្រៀងអាយ៉ៃ គឺមិនមែនអាចចេះច្រៀងបានគ្រប់មនុស្សនោះទេ ទាល់តែអ្នកនោះចេះដល់កម្រិត ដែលអាចបកស្រាយបានពីខ្លឹមសារបានយ៉ាងក្បោះក្បាយ ទើបធ្វើឱ្យគេចង់ស្ដាប់ ។ ចម្រៀងអាយ៉ៃ ផ្ដល់នូវខ្លឹមសារអត្ថប្រយោជន៍ក្នុងន័យអប់រំកូន-គ្រួសារ និងពាក្យពេចន៍ដ៏ថ្លៃថ្នូរ ដែលអ្នកស្ដាប់ អាចយកទៅអនុវត្តតាមបាន ។ ការច្រៀងនេះ គឺត្រូវចំណាយពេល ពី១ម៉ោងទៅ១ម៉ោងកន្លះ ប៉ុន្តែនៅសម័យដើម គេច្រៀងរហូតពី២ម៉ោងកន្លះ ទៅ៣ម៉ោង ។

## អំណាន

### រឿងផ្កាស្រពោន



រឿងផ្កាស្រពោនជាប្រលោមលោកមនោសញ្ចេតនា ដ៏កំសត់ដែលនិពន្ធឡើងដោយលោកនូ ហាច ។ ក្នុងផ្ទៃរឿងទាំងមូលឆ្លុះបញ្ចាំង ពីមនោ-សញ្ចេតនាស្មោះត្រង់ របស់យុវជនប៊ុន ធឿន និងតរុណីវិធាវី ។ ស្នេហានេះកើតចេញពីសេច-ក្ដីរាប់អានដែលមានតាំងពីវ័យកុមារផង និងអំពីការផ្សំផ្គុំរបស់ឪពុកម្ដាយផង តែនៅទីបញ្ចប់ គូសង្សារទាំងពីរនេះត្រូវព្រាត់គ្នាជារៀងរហូត គ្មានថ្ងៃជួបវិញ ។

តាមរយៈរឿងផ្កាស្រពោន យើងអាចសន្និដ្ឋានថា លោកនូហាច គឺជាអ្នកនិពន្ធដែលមានគំនិតជឿនលឿន ។ ស្នេហាប៊ុន ធឿន និងវិធាវី ជាឧទាហរណ៍មួយសម្រាប់មាតាបិតាក៏ដូចជា យុវជន-នារីទាំងឡាយ យកទៅត្រិះរិះពិចារណាមុននឹងសម្រេចចិត្តធ្វើអ្វីមួយ ដូចជា ( ការទុកដាក់កូនចៅ ការជឿលើជំនឿអរូបិយ៍គ្មានព្រំដែន ភាពក្លាហានក្នុងការបញ្ចេញមតិជុំវិញការជ្រើសរើសគូស្រករ... ) ។

ក្រៅអំពីសាច់រឿងដ៏មានខ្លឹមសារ អ្នកនិពន្ធក៏មានទឹកដៃខ្ពស់ក្នុងការប្រើប្រាស់សំនួនពាក្យពេចន៍ ដែលញុំាងឱ្យខ្សែរឿងនេះកាន់តែលន្លង់លន្លោចឡើងថែមទៀត ។

### រឿងអំបែងអណ្ដែត



រឿងអំបែងអណ្ដែត គ្រាន់តែអានចំណងជើងរឿងនេះភ្លាម យើងក៏អាចស្មានដឹងខ្លះៗ អំពីអ្វីដែលអ្នកនិពន្ធកែវ ច័ន្ទ បូរណ៍នឹងបង្ហាញនៅក្នុងដំណើររឿងនះ ។

ផ្ទៃរឿងទាំងមូលលាតត្រដាងអំពីការតស៊ូរបស់នាងរាសីដែលទទួលភារៈចិញ្ចឹមបីបាច់ថែរក្សាប្អូនៗ ។ ផ្ទុយស្រឡះអំពីយុវតីមួយចំនួន ដែលបណ្ដែតបណ្ដោយខ្លួនឱ្យធ្លាក់ទៅក្នុងភក់ជ្រាំ ព្រោះតែភាពក្រីក្រ ការលោភលន់ និងក្ដីអស់សង្ឃឹម ។ រាសីបានប្រើប្រាជ្ញាដ៏ឈ្លាសវៃ និងកម្លាំងញើសឈាមរបស់ខ្លួនដើម្បីស្រោចស្រង់គ្រួសារ ព្រមទាំងរកបាននូវអនាគតល្អមួយ សម្រាប់ខ្លួនឯង ។ ថ្វីត្បិតរាសីមិនមែនជានារីស្លូតស្រគត់ស្រគំ តែនាងមានគុណសម្បត្តិ ជាច្រើនដែលអាចនឹងចាត់ទុកថា ជាស្ត្រីដ៏ល្អមួយរូប ។

ហើយអ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុតនៅក្នុងរឿងនេះ គឺការបញ្ចប់រឿងរបស់អ្នកនិពន្ធ ។ រាសីមិនបានក្លាយទៅជាភរិយានៃអ្នកមានទ្រព្យសម្បត្តិណាមួយឡើយ ប៉ុន្តែនាងមានសមត្ថភាពចិញ្ចឹមជីវិតបានដោយខ្លួនឯង ហើយក៏មានជម្រើសជាច្រើនក្នុងការជ្រើសរើសគូអនាគត ។

**ម៉េង សុមនា**



## ប្រវត្តិសាស្ត្រ




Photo : DR

# អាស៊ាន ក្នុងប្រវត្តិ ៤០ឆ្នាំ របស់ខ្លួន

### អាន ឡូរ៉ី ប៉ូរ៉េ

នៅថ្ងៃទី ០៨ សីហា ឆ្នាំ១៩៦៧ ប្រទេសឥណ្ឌូនេស៊ី ប្រទេសម៉ាឡេស៊ី ប្រទេសហ្វីលីពីន ប្រទេសថៃនិង ប្រទេសសិង្ហបុរី បានចុះហត្ថលេខារួមគ្នានៅទីក្រុងបាងកកនៃប្រទេសថៃ ។ កិច្ចព្រមព្រៀងជាមួយគ្នានេះ បង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា អាស៊ាន ។ គោលដៅគឺចង់អភិវឌ្ឍកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមនិងវប្បធម៌-ល-ព្រមទាំងការពារឱ្យបាននូវ សន្តិភាព និងស្ថេរភាពនៅក្នុងតំបន់នេះ ពីពិភពលោកខាងក្រៅ ដែលត្រូវធ្វើឱ្យរំជើបរំជួលដោយជម្លោះនៅតំបន់ឥណ្ឌូចិន ។ នៅសម័យនោះដែរ សង្គ្រាមត្រជាក់បានកើតឡើងដោយមានការប្រឈមមុខគ្នារវាងមហាអំណាច២ គឺសហភាពសូវៀត និងសហរដ្ឋអាមេរិក ។ ចំណែកសហរដ្ឋអាមេរិក ក៏បានគាំទ្រឱ្យមានការបង្កើតនូវសមាគមអាស៊ាន ដោយគិតថាអាស៊ាននឹងបញ្ឈប់ការរីករាលដាលសាយភាយនៃលទ្ធិកុម្មុយនិស្ត ។ ទោះបីអាស៊ានមិនមានសកម្មភាពច្រើន នៅពេលចាប់ផ្ដើមក៏ដោយ ប៉ុន្តែវាក៏អនុញ្ញាតឱ្យប្រទេសជាសមាជិកអាចដោះស្រាយនូវជម្លោះដែនដីបានមួយចំនួនផងដែរ ។ ប្រឈមមុខទៅនឹងប្លុកនៃប្រទេសកុម្មុយនិស្តនៅឥណ្ឌូចិន អាស៊ានបានរួបរួមគ្នាជុំវិញសន្ធិសញ្ញាសន្តិភាព និងកិច្ចសហប្រតិបត្តិការ រវាងគ្នា និងគ្នា ប៉ុន្តែហាមឃាត់ប្រទេសសមាជិក មិនឱ្យលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់គ្នាផងដែរ ។

ការរលំរលាយនូវប្លុកសូវៀត នៅឆ្នាំ១៩៩០ ក៏បានបង្កើតនូវរបត់ថ្មីមួយទៀត គឺប្រទេសអាស៊ានបានផ្ដួចផ្ដើមគំនិតបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយគ្នា ។ ប្រទេសក្បែរខាង មានវៀតណាម ឡាវ និងកម្ពុជា បានធ្វើសមាហរណកម្មក្នុងសមាគមនេះ ជាបន្តបន្ទាប់ មាននៅឆ្នាំ១៩៩៥ ឆ្នាំ១៩៩៧ ( ជាមួយប្រទេសភូមា) និងនៅឆ្នាំ១៩៩៩ ។ នៅខណៈដែលប្រទេសប្រ៊ុយណេ បានក្លាយជាសមាជិកទីប្រាំមួយរបស់សមាគមអាស៊ានតាំងពីឆ្នាំ១៩៨៤ មកម្ល៉េះ ។ នៅឆ្នាំ២០១១ ខាងមុខ ប្រទេសទីម័រខាងកើតនឹងចូលជាសមាជិករបស់អាស៊ានផងដែរ ។

អាស៊ានដែលតំណាងឱ្យទីផ្សារដែលមានប្រជាជនជិត ៥៥០លាននាក់ បានក្លាយទៅជាអង្គការយ៉ាងសំខាន់មួយប្រចាំតំបន់ ។ អាស៊ានតែងពិភាក្សាក្នុងសំឡេងតែមួយចំពោះប្រធានបទខ្លះ និងចាប់ដៃជាមួយចិន ជប៉ុន ឬកូរ៉េខាងត្បូងដើម្បីឱ្យកាន់តែមានទម្ងន់នៅក្នុងកិច្ចពិភាក្សាជាលក្ខណៈអន្តរជាតិ ។ សម្រាប់អាស៊ានបញ្ហាប្រឈមមុខមានច្រើនដូចជា ការចាត់ចែងកំណើនសេដ្ឋកិច្ច ការប្រកាន់សាសនា ការពង្រឹងសន្តិសុខ ភាពតានតឹងរវាងប្រទេស និងប្រទេស និងជម្លោះដណ្ដើមធនធាននៅសមុទ្រចិនខាងត្បូង ( ជាពិសេសធនធានប្រេងកាត) ។ ថែមពីលើនេះ អាស៊ានក៏ប្រឈមមុខទៅនឹងការរិះគន់លើកង្វះសកម្មភាពរបស់ខ្លួន ជាពិសេសនៅលើបញ្ហាប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។ សហភាពអឺរ៉ុបធ្លាប់ស្ដីបន្ទោសដល់អាស៊ានដែលមិនបានដាក់ទណ្ឌកម្មលើប្រទេសភូមា បន្ទាប់ពីមានការបង្ក្រាបដោយបង្ហូរឈាមកាលពីខែកញ្ញា ឆ្នាំ២០០៧ ។

### របត់ក្នុងទសវត្សរ៍ ឆ្នាំ១៩៨០

**បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម កងទ័ពវៀតណាមបន្តឋិតនៅកម្ពុជា។ ស្ថានភាពនេះបង្កឱ្យមានភាពខ្វែងគំនិតគ្នាក្នុងចំណោមប្រទេសអាស៊ាន។ ខ្លះចង់ឱ្យមានការប្រតិកម្មខ្លាំងក្លា ខ្លះទៀតជ្រើសរើសនិន្នាការសម្របសម្រួល។ ជាចុងក្រោយពួកគេសម្រេចឯកកោប្រទេសវៀតណាម ដោយទុកលទ្ធភាពឱ្យវៀតណាម ចរចាដើម្បីធ្វើមាតុភូមិនិវត្តន៍កងទ័ពទៅប្រទេសខ្លួនវិញ។ ពួកគេបានត្រាប្រណីឱ្យក្រុមខ្មែរក្រហម និងគាំទ្ររដ្ឋាភិបាលរួបរួមនៅក្នុងទសវត្សរ៍ទី៨០។ កិច្ចពិភាក្សាស្វែងរកមតិស្របគ្នាពីបញ្ហានេះនាំឱ្យអាស៊ានអាចពង្រឹងចំណងទាក់ទងនយោបាយផ្ទៃក្នុង និងអះអាងគោលជំហររបស់ខ្លួនលើឆាកអន្តរជាតិ។**

Fevrier-2008.qxd 2/20/2008 11:22 AM Page 16

# ល្បែងកំសាន្ត

*សូមប្អូនពិនិត្យរូបភាពទាំងពីរនេះឱ្យបានច្បាស់។ វាមានលក្ខណៈ ដូចគ្នា ប៉ុន្តែនៅក្នុងនោះ មាន ៧ចំនុចខុសគ្នា។ សាកល្បងរកមើល !*

*ចំនុចខុសគ្នា*



## ប្អូនៗអាចរៀនគូររូបសត្វទន្សាយ និងខ្លា ជាសត្វរស់នៅក្នុងព្រៃតាមដំណាក់កាលនីមួយៗ ដូចខាងក្រោមនេះ ។

*ទន្សាយ*



*ខ្លា*



## គម្រោងការប្រចាំខែ

- ក្នុងខែកុម្ភៈនេះ : ព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច)-ភ្នំពេញ ចាប់ផ្តើមជួលជុលផ្ទះជូនដល់គ្រួសារអ្នកក្រីក្រចំនួន ៦ផ្ទះ ដែលត្រូវចំណាយថវិកាអស់ ១៩៤៦ដុល្លារ។ ថវិកានេះបានមកពីការចូលរួមវិភាគទានរបស់បងប្អូនគ្រីស្តបរិស័ទក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត។
- ខែកុម្ភៈនេះដែរ : មានដំណើរទស្សនកិច្ចរបស់ភ្ញៀវជាជនជាតិអង់គ្លេសភាគខាងកើតទៅកាន់ព្រះសហគមន៍សៀមរាប ភូមិភាគបាត់ដំបង។
- នៅក្នុងសប្តាហ៍ : រៀងរាល់ថ្ងៃព្រហស្បតិ៍ ព្រះសហគមន៍សន្តយ៉ូសែប មានរៀបចំពិធីថ្វាយអភិបូជានៅពេលម៉ោង ៨ព្រឹក និងរាល់ល្ងាច ថ្ងៃសុក្រម៉ោង ៤រសៀល មានរៀបចំពិធីដើរឈើឆ្កាងនៅក្នុងព្រះវិហារធំ។
- ថ្ងៃទី១៧ កុម្ភៈ : មានពិធីសំណាក់ធម៌រិះគិតអំពីព្រះបន្ទូលដែលរៀបចំដោយព្រះសហគមន៍កាតូលិកសន្តយ៉ូសែប និងធ្វើឡើងនៅវេលាម៉ោង៥:៣០នាទី នាពេលរសៀល។
- ថ្ងៃទី២១ កុម្ភៈ : មានដំណើរទស្សនកិច្ចរបស់ម្ចាស់ក្សត្រីយានីនៃប្រទេសអេស្ប៉ាញទៅកាន់ព្រះសហគមន៍កាតូលិកបាត់ដំបង។
- ថ្ងៃទី២៤ កុម្ភៈ : ព្រះសហគមន៍សន្តយ៉ូសែប រៀបចំពិធីជម្រះចិត្តដល់បងប្អូនដែលរៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកចំនួន ១៦នាក់។
- ថ្ងៃទី២-៧ មីនា : សំណាក់ធម៌រិះគិតពីព្រះបន្ទូលព្រះជាម្ចាស់ រៀបចំដោយព្រះសហគមន៍កំពង់ចាមក្រុងនៅព្រះសហគមន៍កោះរកា។
- ថ្ងៃទី០៨-១០ មីនា : សិក្ខាសាលាគ្រូអប់រំជំនឿភូមិភាគទាំងបីនៃព្រះសហគមន៍កាតូលិកនៅព្រះសហគមន៍កំពង់ចាមក្រុង ដែលមានគ្រូអប់រំជំនឿប្រមាណជា ៦០នាក់ ចូលរួម។
- ថ្ងៃទី១២ មីនា : ប្រជុំអន្តរនិកាយគ្រីស្តសាសនានៅខេត្តកំពង់ចាម។
- ថ្ងៃទី៣០ មីនា : ព្រះសហគមន៍ភូមិភាគភ្នំពេញមានរៀបចំប្រជុំធំមួយដើម្បីឱ្យគ្រីស្ត-បរិស័ទជួបជុំគ្នា ចែកចាយបទពិសោធន៍ដែលនឹងមានគ្រីស្តបរិស័ទចូលរួមប្រមាណ ៣០០០នាក់ នៅសាលាដុនបូស្កូ ភ្នំពេញថ្មី។
- ក្នុងឆ្នាំនេះ : មានអ្នកទទួលអគ្គសញ្ញាជ្រមុជទឹកនៅភូមិភាគបាត់ដំបងចំនួន ៨៤នាក់- ភូមិភាគភ្នំពេញចំនួន ២២នាក់ និងភូមិភាគកំពង់ចាម ១៧នាក់ សរុបទាំងបីភូមិភាគគឺ ១២៣នាក់។